## ការកំណត់តំបន់សហគមន៍ស្ថិតក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព មានផ្ទៃដីចំនួន ៥.០០០(ប្រាំពាន់)ហិកតា ស្ថិតក្នុងភូមិសាស្ត្រ ឃុំយាង និងឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ ._**

ត្រូវបានកំណត់ជាតំបន់សហគមន៍នៃដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព លើផ្ទៃដីសរុបចំនួន ៥.០០០ (ប្រាំពាន់) ហិកតា សម្រាប់ផ្តល់ជូនប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋាន ស្ថិតនៅក្នុងភូមិធម្មជាតិសម្តេចតេជោ ហ៊ុន សែន ឃុំយាង និងឃុំកន្ទួត ស្រុកជាំក្សាន្ត ភូមិសាស្ត្រខេត្តព្រះវិហារ ដែលមានទីតាំងកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមានចំណុចគោលតាមនិយាមកាដូចខាងក្រោមៈ

| No | UTM-X | UTM-Y | No | UTM-X | UTM-Y |
|---|---|---|---|---|---|
| 1 | 473193 | 1570559 | 23 | 472009 | 1568286 |
| 2 | 474151 | 1570559 | 24 | 472062 | 1568327 |
| 3 | 474151 | 1565364 | 25 | 472163 | 1568342 |
| 4 | 472276 | 1565364 | 26 | 472287 | 1568393 |
| 5 | 472276 | 1560374 | 27 | 472402 | 1568453 |
| 6 | 465656 | 1560374 | 28 | 472529 | 1568489 |
| 7 | 465656 | 1564219 | 29 | 472697 | 1568533 |
| 8 | 466681 | 1565174 | 30 | 472824 | 1568533 |
| 9 | 466681 | 1565852 | 31 | 472902 | 1568579 |
| 10 | 469620 | 1565852 | 32 | 473301 | 1568666 |
| 11 | 469620 | 1568173 | 33 | 473301 | 1568650 |
| 12 | 470496 | 1568857 | 34 | 473501 | 1568650 |
| 13 | 470563 | 1568828 | 35 | 473769 | 1569170 |
| 14 | 470591 | 1568829 | 36 | 473769 | 1569409 |
| 15 | 470665 | 1568753 | 37 | 473121 | 1569409 |
| 16 | 470766 | 1568554 | 38 | 473121 | 1569555 |
| 17 | 471027 | 1568511 | 39 | 472106 | 1569555 |
| 18 | 471150 | 1568458 | 40 | 472106 | 1569915 |
| 19 | 471369 | 1568322 | 41 | 472908 | 1569915 |
| 20 | 471489 | 1568290 | 42 | 472908 | 1570335 |
| 21 | 471784 | 1568302 | 43 | 473193 | 1570235 |
| 22 | 471878 | 1568268 | | | |

**មាត្រា២ ..**

តំបន់សហគមន៍នៃដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ត្រូវបានកំណត់ជាតំបន់គ្រប់គ្រងបម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច របស់ប្រជាពលរដ្ឋមូលដ្ឋាន។ រាល់ការចេញប័ណ្ណសម្គាល់សិទ្ធិដីធ្លី ឬ ការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លីនៅក្នុងតំបន់នេះត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថាន ដោយអនុលោមតាមច្បាប់ភូមិបាល។

**មាត្រា៣ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមករា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**អន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ឧបសម្ព័ន្ធ៖ អនុក្រឹត្យលេខ: ០៤...អនក្រ.បក
ចុះថ្ងៃទី ..០៧.... ខែ ..មករា.. ឆ្នាំ ២០១៦...

**ផែនទី កំណត់តំបន់សហគមន៍ នៃតំបន់ដែនជម្រកសត្វព្រៃ គូលែន-ព្រហ្មទេព មានផ្ទៃដីចំនួន ៥០០០ (ប្រាំពាន់) ហិកតា សម្រាប់ផ្តល់ជូនប្រជាពលរដ្ឋ ភូមិធម្មជាតិសម្តេចតេជោ ហ៊ុន សែន ស្ថិតក្នុងភូមិសាស្ត្រឃុំឃាន និងឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ**




| ID | X | Y |
|---|---|---|
| 1 | 473193 | 1570559 |
| 2 | 474151 | 1570559 |
| 3 | 474151 | 1565364 |
| 4 | 472276 | 1565364 |
| 5 | 472276 | 1560374 |
| 6 | 465656 | 1560374 |
| 7 | 465656 | 1564219 |
| 8 | 466681 | 1565174 |
| 9 | 466681 | 1565852 |
| 10 | 469620 | 1565852 |
| 11 | 469620 | 1568173 |
| 12 | 470496 | 1568857 |
| 13 | 470563 | 1568828 |
| 14 | 470591 | 1568829 |
| 15 | 470665 | 1568753 |
| 16 | 470766 | 1568554 |
| 17 | 471027 | 1568511 |
| 18 | 471150 | 1568458 |
| 19 | 471369 | 1568322 |
| 20 | 471489 | 1568290 |
| 21 | 471784 | 1568302 |
| 22 | 471878 | 1568268 |
| 23 | 472009 | 1568286 |
| 24 | 472062 | 1568327 |
| 25 | 472163 | 1568342 |
| 26 | 472287 | 1568393 |
| 27 | 472402 | 1568453 |
| 28 | 472529 | 1568489 |
| 29 | 472697 | 1568533 |
| 30 | 472824 | 1568533 |
| 31 | 472902 | 1568579 |
| 32 | 473301 | 1568666 |
| 33 | 473301 | 1568650 |
| 34 | 473501 | 1568650 |
| 35 | 473769 | 1569170 |
| 36 | 473769 | 1569409 |
| 37 | 473121 | 1569409 |
| 38 | 473121 | 1569555 |
| 39 | 472106 | 1569555 |
| 40 | 472106 | 1569915 |
| 41 | 472908 | 1569915 |
| 42 | 472908 | 1570335 |
| 43 | 473193 | 1570235 |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :..០៣..អនក្រ.បក**

**អនុក្រឹត្យ**
**ស្តីពី**
**ការរៀបចំនិងការប្រព្រឹត្តទៅ**
**នៃគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ**

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងធានាតម្លាភាព អព្យាក្រឹតភាព នីត្យានុកូលភាពហិរញ្ញវត្ថុ និងភាពជឿទុកចិត្តបាន នៃការដោះស្រាយវិវាទសារពើពន្ធ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ ដែលសរសេរជាអក្សរកាត់ថា “គ.វ.ស.” ស្របតាមមាត្រា២៤ នៃច្បាប់ស្ដីពីគយ និងមាត្រា១២៣ នៃច្បាប់ស្ដីពីសារពើពន្ធ។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្ត ចំពោះវិវាទគយ រដ្ឋាករ និងពន្ធដារ ដែលកើតចេញពីការមិនពេញចិត្ត របស់អ្នកជាប់ពន្ធ ចំពោះសេចក្ដីសម្រេច ឬវិធានការចុងក្រោយ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ។

## ជំពូកទី២

## សមាសភាព និងភារកិច្ច

**មាត្រា៤.-**

**គ.វ.ស.** មានសមាសភាព ដូចតទៅ÷

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ០១ រូប | អនុប្រធាន |
| ៣-តំណាងក្រុមប្រឹក្សាជាតិគណនេយ្យ ០១ រូប | សមាជិក |
| ៤-អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ៥-អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក។ |

សមាសភាពជាក់ស្ដែងនៃ **គ.វ.ស.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥.-**

**គ.វ.ស.** មានភារកិច្ច ដូចតទៅ÷

- ពិនិត្យ ដោះស្រាយ និងសម្រេច លើបណ្ដឹងតវ៉ារបស់អ្នកជាប់ពន្ធ ដែលមិនពេញចិត្ត ចំពោះសេចក្ដីសម្រេច ឬវិធានការចុងក្រោយ របស់អគ្គនាយកដ្ឋានពន្ធដារ ពាក់ព័ន្ធវិវាទពន្ធដារ ដែលបង្កើតជាកាតព្វកិច្ចចំពោះសាមីអ្នកប្ដឹងតវ៉ាផ្ទាល់

- ពិនិត្យ ដោះស្រាយ និងសម្រេច លើបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធ ដែលមិនពេញចិត្ត ចំពោះសេចក្តីសម្រេច ឬ វិធានការចុងក្រោយ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ពាក់ព័ន្ធវិវាទគយនិងរដ្ឋាករ ដែលបង្កើតជាកាតព្វកិច្ចចំពោះសាមីអ្នកប្តឹងតវ៉ាផ្ទាល់
- ពិនិត្យ ដោះស្រាយ និងសម្រេច លើសេចក្តីសម្រេចឬវិធានការពាក់ព័ន្ធវិវាទសារពើពន្ធចុងក្រោយផ្សេងទៀត ដែលបង្កើតជាកាតព្វកិច្ចចំពោះសាមីអ្នកប្តឹងតវ៉ាផ្ទាល់។

## ជំពូកទី៣
## កិច្ចដំណើរការ

**មាត្រា៦.-**

សមាសភាព **គ.ទ.ស.** ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានត្រូវកោះអញ្ជើញ និងដឹកនាំការប្រជុំ **គ.ទ.ស.** តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**មាត្រា៧.-**

**គ.ទ.ស.** មានសិទ្ធិអញ្ជើញមន្ត្រីជំនាញពាក់ព័ន្ធ នៃក្រសួង ស្ថាប័ន សវនករ តំណាងវិស័យឯកជនពាក់ព័ន្ធ ដើម្បីបំភ្លឺ ឬផ្តល់យោបល់ តាមការចាំបាច់។

អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានភារកិច្ចបំភ្លឺលើពាក្យបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធ តាមការអញ្ជើញរបស់ **គ.ទ.ស.**។

**មាត្រា៨.-**

**គ.ទ.ស.** មានលេខាធិការដ្ឋានមួយ ជាសេនាធិការ ក្នុងការបំពេញមុខងាររបស់ខ្លួន។

លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាលេខាធិការដ្ឋាន **គ.ទ.ស.** ដោយមានភារកិច្ច ដូចខាងក្រោម÷

- សម្របសម្រួលការងាររដ្ឋបាល និងធានាកិច្ចដំណើរការរបស់ **គ.ទ.ស.**
- ទទួល ចុះបញ្ជី និងគ្រប់គ្រងពាក្យបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធ
- ពិនិត្យនិងសិក្សាស្រាវជ្រាវ លើពាក្យបណ្តឹងតវ៉ា ឯកសារ ព័ត៌មាន និងភស្តុតាងពាក់ព័ន្ធ
- តាមការអញ្ជើញរបស់ **គ.ទ.ស.** ធ្វើការជាមួយមន្ត្រីជំនាញពាក់ព័ន្ធ នៃក្រសួង ស្ថាប័ន សវនករ តំណាងវិស័យឯកជនពាក់ព័ន្ធ និងអ្នកប្តឹងតវ៉ា ដើម្បីទទួលបានការបំភ្លឺ ឬការផ្តល់ភស្តុតាងបន្ថែម សម្រាប់ជាមូលដ្ឋាននៃការរៀបចំរបាយការណ៍ជូន **គ.ទ.ស.**
- លើកសំណើដោះស្រាយបណ្តឹងតវ៉ា ជូនប្រធាន **គ.ទ.ស.** ពិនិត្យ និងសម្រេច។

**មាត្រា៩.-**

**គ.ទ.ស.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបំពេញការងាររបស់ខ្លួន។

## ជំពូកទី៤
## នីតិវិធីដោះស្រាយបណ្តឹងតវ៉ា

**មាត្រា១០.-**

អ្នកជាប់ពន្ធដែលមិនពេញចិត្តនឹងសេចក្តីសម្រេច ឬវិធានការ ដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ មានសិទ្ធិដាក់ពាក្យបណ្តឹង ទៅអគ្គនាយកដ្ឋានពន្ធដារ ក្នុងរយៈពេល ៣០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទ ដែលអ្នកជាប់ពន្ធបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេច ឬវិធានការ របស់អគ្គនាយកដ្ឋានពន្ធដារ។

អ្នកជាប់ពន្ធដែលមិនពេញចិត្តនឹងសេចក្តីសម្រេច ឬវិធានការ ដែលចេញដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានសិទ្ធិដាក់ពាក្យបណ្តឹង ទៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងរយៈពេល ៣០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទ ដែលអ្នកជាប់ពន្ធបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេច ឬវិធានការ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**មាត្រា១១.-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឬអគ្គនាយកដ្ឋានពន្ធដារ ត្រូវពិនិត្យ ដោះស្រាយ សម្រេច ឬមានវិធានការឆ្លើយតប លើពាក្យបណ្តឹងរបស់អ្នកជាប់ពន្ធ ក្នុងរយៈពេលមិនលើសពី ៦០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទ នៃការទទួលពាក្យបណ្តឹង។

វិធាននិងនីតិវិធីនៃការដោះស្រាយវិវាទគយនិងរដ្ឋាករ នៅកម្រិតអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ព្រមទាំងវិធាននិងនីតិវិធីនៃការដោះស្រាយវិវាទពន្ធដារ នៅកម្រិតអគ្គនាយកដ្ឋានពន្ធដារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១២.-**

អ្នកជាប់ពន្ធដែលមិនពេញចិត្ត ចំពោះសេចក្តីសម្រេច ឬវិធានការចុងក្រោយរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឬអគ្គនាយកដ្ឋានពន្ធដារ មានសិទ្ធិប្តឹងតវ៉ាមក **គ.ទ.ស.** ក្នុងរយៈពេល ៣០ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលលិខិតជូនដំណឹងស្តីពីសេចក្តីសម្រេចដោះស្រាយបណ្តឹងតវ៉ា ឬវិធានការចុងក្រោយរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឬអគ្គនាយកដ្ឋានពន្ធដារ ដោយចម្លងជូនសាមីអគ្គនាយកដ្ឋាន។

**មាត្រា១៣.-**

អ្នកជាប់ពន្ធ ត្រូវដាក់ពាក្យបណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សរ នៅលេខាធិការដ្ឋាន **គ.ទ.ស.**។

ពាក្យបណ្តឹងតវ៉ា ត្រូវមានព័ត៌មាន កម្មវត្ថុ និងមូលហេតុនៃបណ្តឹង ជាអាទិ៍ ដូចខាងក្រោម÷

- ឈ្មោះ អាសយដ្ឋាន និងលេខអត្តសញ្ញាណកម្មសារពើពន្ធ នៃអ្នកជាប់ពន្ធដែលធ្វើការតវ៉ា
- ព័ត៌មានលម្អិតនៃសេចក្តីសម្រេច ឬវិធានការ ដែលជាកម្មវត្ថុនៃការតវ៉ា
- ដើមហេតុ ឬអំពើដែលជាកម្មវត្ថុនៃការតវ៉ា
- ហេតុផល ឬមូលដ្ឋានគតិយុត្តនៃការតវ៉ា
- កាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកជាប់ពន្ធ ឬអ្នកតំណាងរបស់អ្នកជាប់ពន្ធ
- ឯកសារ ព័ត៌មាន លិខិតយុត្តិការ និងភ័ស្តុតាងចាំបាច់ដែលជាមូលដ្ឋាន នៃការតវ៉ា

- ឯកសារ ព័ត៌មាន លិខិតយុត្តិការ និងភ័ស្តុតាងផ្សេងទៀត ពាក់ព័ន្ធនឹងការតវ៉ា តាមការកំណត់របស់ **គ.ទ.ស.**។

គំរូនៃពាក្យបណ្តឹងតវ៉ា ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៤.-**

ក្នុងករណីពាក្យបណ្តឹងតវ៉ាពុំបំពេញតាមលក្ខខណ្ឌកំណត់ក្នុងមាត្រា១៣ នៃអនុក្រឹត្យនេះ លេខាធិការដ្ឋាន **គ.ទ.ស.** ត្រូវស្នើសុំឱ្យអ្នកប្តឹងតវ៉ា បំពេញចំណុចដែលខ្វះខាត។

**គ.ទ.ស.** អាចចេញសេចក្តីសម្រេចបដិសេធពាក្យបណ្តឹងតវ៉ា ក្នុងករណីលក្ខខណ្ឌនៃការដាក់ពាក្យបណ្តឹងតវ៉ាពុំត្រូវបានបំពេញគ្រប់គ្រាន់ដោយអ្នកប្តឹងតវ៉ា។

**មាត្រា១៥.-**

បន្ទាប់ពីទទួលបានពាក្យបណ្តឹងតវ៉ា លេខាធិការដ្ឋាន **គ.ទ.ស.** ពិនិត្យ ស្រាវជ្រាវ និងរៀបចំរបាយការណ៍ស្តីពីបណ្តឹងតវ៉ា ជូន **គ.ទ.ស.**។

**មាត្រា១៦.-**

ការដោះស្រាយវិវាទសារពើពន្ធ អាចឆ្លងកាត់ការសម្រុះសម្រួលជាមុន ទៅតាមកម្រិត ដូចខាងក្រោម÷

- ក្នុងកម្រិតអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឬអគ្គនាយកដ្ឋានពន្ធដារ ការសម្រុះសម្រួលត្រូវសម្រេចដោយអគ្គនាយកនៃសាមីអគ្គនាយកដ្ឋាននីមួយៗ។
- ក្នុងកម្រិត **គ.ទ.ស.** ការសម្រុះសម្រួលត្រូវសម្រេចដោយប្រធាន **គ.ទ.ស.**។

ការសម្រុះសម្រួល ត្រូវធ្វើឡើងក្នុងរយៈពេលមិនលើសពី ៣០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទ នៃការទទួលពាក្យបណ្តឹង ឬក្នុងរយៈពេលសមស្រប អាស្រ័យលើទំហំនិងប្រភេទរឿងនីមួយៗ។

**មាត្រា១៧.-**

ក្នុងការដោះស្រាយវិវាទ **គ.ទ.ស.** ពិនិត្យទាំងលើអង្គហេតុ និងអង្គច្បាប់។

ក្នុងករណីចាំបាច់ ប្រធាន **គ.ទ.ស.** អាចសម្រេចឱ្យមានការស្រាវជ្រាវបន្ថែមឬអធិការកិច្ចលើពាក្យបណ្តឹងតវ៉ាដើម្បីបញ្ជាក់ ឬប្រមូលព័ត៌មាន ឬភ័ស្តុតាងបន្ថែមពាក់ព័ន្ធអង្គហេតុ។

**មាត្រា១៨.-**

**គ.ទ.ស.** ត្រូវពិនិត្យនិងសម្រេចដោះស្រាយបណ្តឹងតវ៉ា ក្នុងរយៈពេលមិនលើសពី ៦០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទ នៃការទទួលពាក្យបណ្តឹង ឬក្នុងរយៈពេលសមស្រប អាស្រ័យលើទំហំនិងប្រភេទរឿងនីមួយៗ។

**មាត្រា១៩.-**

ក្នុងករណីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ **គ.ទ.ស.** អ្នកជាប់ពន្ធអាចដាក់ពាក្យបណ្តឹងតវ៉ា ទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល ៣០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទ នៃការទទួលលិខិតជូនដំណឹងស្តីពីសេចក្តីសម្រេចរបស់ **គ.ទ.ស.** ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

បណ្តឹងរបស់អ្នកជាប់ពន្ធ ទៅតុលាការ ពុំមានអានុភាពផ្អាកការអនុវត្តសេចក្តីសម្រេចរបស់ **គ.ទ.ស.** ឡើយ។

**មាត្រា២០.-**

**គ.ទ.ស.** ត្រូវចាត់តំណាងរបស់ខ្លួន នៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការ ក្រោមការដឹកនាំនិងសម្របសម្រួលរបស់ក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា២១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:....០៤....អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

**សម្រេច**

**មាត្រា១**.-បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន១៣រូប ដែលមានស្នាដៃល្អក្នុងការចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា ស្ថិតនៅវត្តចំប៉ា ឃុំច្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

| | | |
|---|---|---|
| ១-លោក | **ម៉ូ ច័ន្ទសុំណា** | ប្រធានការិយាល័យធម្មការនិងសាសនាស្រុកកំពង់ត្រឡាច |
| ២-លោក | **ប្រាក់ ថន** | មេឃុំច្រេស |
| ៣-លោក | **កង រុន** | ជំទប់ទី១ ឃុំច្រេស |
| ៤-លោក | **កង សុខ** | ជំទប់ទី២ ឃុំច្រេស |
| ៥-លោក | **ព្រុំ ចេង** | ក្រុមប្រឹក្សាឃុំច្រេស |
| ៦-លោក | **ឆេង ថុន** | អតីតប្រធានការិយាល័យធម្មការស្រុកកំពង់ត្រឡាច |

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ**

| | | |
|---|---|---|
| ១-លោក | **លាវ ពិសិដ្ឋ** | ប្រធាននាយកដ្ឋានក្រសួងយុត្តិធម៌ |
| ២-លោក | **ចេង សុខមាន** | ប្រធានការិយាល័យក្រសួងយុត្តិធម៌ |
| ៣-ឧបាសក | **អ៊ិន ស៊ុម** | ប្រធានគណៈកម្មការវត្តចំប៉ា |
| ៤-ឧបាសក | **ម៉ែន មិន** | អនុប្រធានគណៈកម្មការវត្តចំប៉ា |
| ៥-ឧបាសក | **កើត ស៊ីន** | អាចារ្យវត្តចំប៉ា |
| ៦-ឧបាសក | **កង ស៊ីន** | អាចារ្យវត្តចំប៉ា |
| ៧-ឧបាសក | **ម៉ី គេង** | អាចារ្យវត្តចំប៉ា |

**មាត្រា២**.-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...០៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

## សម្រេច

**មាត្រា១.**-បំពាក់ **មេដាយមាសការងារ** ជូនសប្បុរសជន ចំនួន០៥រូប ដែលមានស្នាដៃល្អក្នុងការចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា ស្ថិតនៅវត្តចំប៉ា ឃុំច្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោម ៖

១-លោក **ប៊ិត ចាន់ខន**

២-លោក **យាន នៅ**

៣-លោក **ហ៊ីល សុផាត**

៤-លោក **ផន ចណ្ណី**

៥-លោក **ខឿន រតនា**

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:...០២...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

### សម្រេច

**មាត្រា១.**.បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន២៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា ស្ថិតនៅវត្តចំប៉ា ឃុំច្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិ**

| | | |
|---|---|---|
| ១-លោក **គង់ ម៉េងហៀង** | សប្បុរសជន នៅរាជធានីភ្នំពេញ | ថវិកាចំនួន១០,០០០ដុល្លារ |
| ២-លោក **សុខ ឡើន** | សប្បុរសជន នៅប្រទេសញូវស៊ីឡែន | ថវិកាចំនួន១០,០០០ដុល្លារ |
| ៣-ឧបាសក **ប្រាក់ សាមិត្ត** | សប្បុរសជន នៅស្រុកកំពង់ត្រឡាច | ថវិកាចំនួន១០,០០០ដុល្លារ |
| ៤-លោក **អ៊ុក ញ៉ាន** | សប្បុរសជន នៅរាជធានីភ្នំពេញ | ថវិកាចំនួន១០,០០០ដុល្លារ |

**ខ-មេដាយសំរឹទ្ធស្ថាបនាជាតិ**

| | |
|---|---|
| ១-ឧបាសក **ឃិត ឃៀង** | គណៈកម្មការវត្តចំប៉ា |
| ២-ឧបាសក **ម៉ែន ផន** | គណៈកម្មការវត្តចំប៉ា |
| ៣-ឧបាសក **ស៊ឹម ឌឹម** | គណៈកម្មការវត្តចំប៉ា |
| ៤-ឧបាសក **នួរ ហេង** | គណៈកម្មការវត្តចំប៉ា |
| ៥-ឧបាសក **ឃឹម អាន់** | គណៈកម្មការវត្តចំប៉ា |
| ៦-ឧបាសក **អ៊ួន ហៃ** | គណៈកម្មការវត្តចំប៉ា |
| ៧-ឧបាសក **គឹម សាន** | សមាជិកគណៈកម្មការវត្តចំប៉ា |
| ៨-ឧបាសក **អ៊ុម ឡើន** | សមាជិកគណៈកម្មការវត្តចំប៉ា |
| ៩-ឧបាសក **ស្រី ឃីម** | សមាជិកគណៈកម្មការវត្តចំប៉ា |

១០-ឧបាសក **អ៊ុំម យឿន** សមាជិកគណៈកម្មការវត្តចំប៉ា
១១-ឧបាសក **ស្វរ មួយ** សមាជិកគណៈកម្មការវត្តចំប៉ា
១២-ឧបាសក **ជុំ ទឹក** សមាជិកគណៈកម្មការវត្តចំប៉ា
១៣-ឧបាសក **ជួប ស៊ុយ** សមាជិកគណៈកម្មការវត្តចំប៉ា
១៤-ឧបាសក **ម៉ា យ៉ឺន** សមាជិកគណៈកម្មការវត្តចំប៉ា
១៥-ឧបាសិកា **អ៊ុំម សាម៉ៃ** សមាជិកាគណៈកម្មការវត្តចំប៉ា
១៦-ឧបាសិកា **សែន នី** សមាជិកាគណៈកម្មការវត្តចំប៉ា
១៧-ឧបាសិកា **ចាន់ រ៉េត** សមាជិកាគណៈកម្មការវត្តចំប៉ា
១៨-ឧបាសិកា **សាន់ សេត** សមាជិកាគណៈកម្មការវត្តចំប៉ា
១៩-ឧបាសិកា **ចាន់ ស្រៀន** សមាជិកាគណៈកម្មការវត្តចំប៉ា
២០-ឧបាសិកា **ផាច ជា** សមាជិកាគណៈកម្មការវត្តចំប៉ា
២១-លោក **សាន់ សម្ភាជ** សមាជិកគណៈកម្មការវត្តចំប៉ា

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...០៣..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម៖

**ក-ដំឡើងឋានន្តរស័ក្តិថ្នាក់វរសេនីយ៍ឯក**

១-វរសេនីយ៍ទោ **ញ៉ែម ពិសុទ្ធ** អត្តលេខ ០០៤៦៤៤ ជំនួយការ ឯកឧត្តម នាយឧត្តមសេនីយ៍ ហ៊ីង ប៊ុនហៀង

២-វរសេនីយទោ **សទ្ធាតសុផល** អត្តលេខ ០១៨២៧២ ជំនួយការ ឯកឧត្តម សឹង សំណាង បញ្ជាការដ្ឋានកងទ័ពជើងអាកាស

៣-វរសេនីយទោ **សុខ សំរឿន** អត្តលេខ ០០២៤៧២ ជំនួយការ ឯកឧត្តម គង់ មុនី បញ្ជាការដ្ឋានកងទ័ពជើងអាកាស

៤-វរសេនីយទោ **ម៉ិញ សារុន** អត្តលេខ ០១៨១៩៣ ជំនួយការ ឯកឧត្តម សោម សាទុម បញ្ជាការដ្ឋានកងទ័ពជើងអាកាស

៥-វរសេនីយទោ **កែវ វណ្ណណា** អត្តលេខ ០១៨២២៦ ជំនួយការ ឯកឧត្តម យិន សុខា
បញ្ជាការដ្ឋានកងទ័ពជើងអាកាស

៦-វរសេនីយទោ **ជា សុផាត** អត្តលេខ ០០២៤៨៦ ជំនួយការ ឯកឧត្តម ពិន ណារិទ្ធ
បញ្ជាការដ្ឋានកងទ័ពជើងអាកាស

៧-វរសេនីយទោ **គឹម ចាន់ថុន** អត្តលេខ ០០២៤៩៧ ជំនួយការ ឯកឧត្តម ម៉ៅ សេង
បញ្ជាការដ្ឋានកងទ័ពជើងអាកាស

៨-វរសេនីយទោ **ម៉ែន សារ៉ែន** អត្តលេខ ០០២៤២៣ ជំនួយការ ឯកឧត្តម សែស វង្សសត្ថា
បញ្ជាការដ្ឋានកងទ័ពជើងអាកាស

៩-វរសេនីយទោ **សុខ ហេង** អត្តលេខ ០០៩១៣១ ជំនួយការ ឯកឧត្តម ឈួន ថាវិន្ទ
បញ្ជាការដ្ឋានកងទ័ពជើងអាកាស

១០-វរសេនីយ៍ទោ **នួន ស៊ីរដ្ឋា** អត្តលេខ ០២៧៣៨៥ នាយរង ការិយាល័យប្រតិបត្តិការ
ស្នងការដ្ឋានប្រតិបត្តិការ បញ្ជាការដ្ឋានកងទ័ពជើងអាកាស

១១-វរសេនីយ៍ទោ **មាស សុខរស្មី** អត្តលេខ ០១៨១៨៧ នាយរង ការិយាល័យប្រតិបត្តិការ
ស្នងការដ្ឋានប្រតិបត្តិការ បញ្ជាការដ្ឋានកងទ័ពជើងអាកាស

១២-វរសេនីយ៍ទោ **ទិត សាត** អត្តលេខ ០១៨១៩០ នាយរង ការិយាល័យប្រតិបត្តិការ
ស្នងការដ្ឋានប្រតិបត្តិការ បញ្ជាការដ្ឋានកងទ័ពជើងអាកាស

១៣-វរសេនីយ៍ទោ **ខួច កុលធីម៉ូ** អត្តលេខ ០២៧៣៩៣ នាយរង ការិយាល័យភស្តុភារ ស្នងការដ្ឋាន
ភស្តុភារ បញ្ជាការដ្ឋានកងទ័ពជើងអាកាស

១៤-វរសេនីយ៍ទោ **ធុច សំអាត** អត្តលេខ ០០៩១៤០ នាយរង ការិយាល័យបច្ចេកទេស
ស្នងការដ្ឋានច្ចេកទេស បញ្ជាការដ្ឋានកងទ័ពជើងអាកាស

១៥-វរសេនីយ៍ទោ **ឃិន ស៊ីផា** អត្តលេខ ០០៩១៥០ នាយរង ការិយាល័យបច្ចេកទេស
ស្នងការដ្ឋានបច្ចេកទេស បញ្ជាការដ្ឋានកងទ័ពជើងអាកាស

**ខ-ដំឡើងឋានន្តរស័ក្តិថ្នាក់វរនាវីឯក**

១-វរនាវីទោ **ម៉ម វីរដ្ឋា** អត្តលេខ ០១៥០១៨ នាយការិយាល័យអប់រំចិត្តសាស្ត្រ
ស្នងការដ្ឋានឃោសនាព័ត៌មាន បញ្ជាការដ្ឋានកងទ័ពជើងទឹក

២-វរនាវីទោ **ចាន់ សារិទ្ធ** អត្តលេខ ០៣១០១៧ ស្នងការរង ស្នងការដ្ឋានបច្ចេកទេស
បញ្ជាការដ្ឋានកងទ័ពជើងទឹក

៣-វរនាវីទោ **ផាន់ អឿន** អត្តលេខ ០១៥០១១ នាយការិយាល័យអាវុធគ្រាប់
ស្នងការដ្ឋានបច្ចេកទេស បញ្ជាការដ្ឋានកងទ័ពជើងទឹក

៤-វរនាវីទោ **ម៉ែន ឈិន** អត្តលេខ ០៤២៧៦៨ នាយការិយាល័យសំភារៈបច្ចេកទេស
ស្នងការដ្ឋានបច្ចេកទេស បញ្ជាការដ្ឋានកងទ័ពជើងទឹក

៥-វរនាវីទោ **លី សុវណ្ណា** អត្តលេខ ០១៥១៥៣ មេបញ្ជាការកងនាវាល្បាតទន្លេ
បញ្ជាការដ្ឋានកងទ័ពជើងទឹក

៦-វរនាវីទោ **លឹម បណ្ឌិត** អត្តលេខ ០៥៥៩២៥ ជំនួយការ ឯកឧត្តម មេបញ្ជាការ
បញ្ជាការដ្ឋានកងទ័ពជើងទឹក

៧-វរនាវីទោ **ខ៉ាន់ ជឿន** អត្តលេខ ០៥៥៨៤៣ ជំនួយការ ឯកឧត្តម មេបញ្ជាការ បញ្ជាការដ្ឋានកងទ័ពជើងទឹក

៨-វរនាវីទោ **ឆាន សំណាង** អត្តលេខ ០១៤៩៩៦ ជំនួយការ ឯកឧត្តម មេបញ្ជាការ បញ្ជាការដ្ឋានកងទ័ពជើងទឹក

៩-វរនាវីទោ **ភុច វ៉េតរំដួល** អត្តលេខ ០១៥១៣១ នាយសេនាធិការរង មូលដ្ឋានសមុទ្រ

១០-វរនាវីទោ **រឿង សុផាតារារិទ្ធ** អត្តលេខ ០១៥០៧៨ នាយសេនាធិការរង មូលដ្ឋានសមុទ្រ

១១-វរនាវីទោ **ស៊ឹម សុផល** អត្តលេខ ០១០២៨៩ នាយសេនាធិការរង មូលដ្ឋានសមុទ្រ

១២-វរនាវីទោ **ភឿក មូរ៉ា** អត្តលេខ ០១៥១៥៩ ប្រធានការិយាល័យគ្រប់គ្រងសភាពការណ៍ នាយកដ្ឋានគ្រប់គ្រងប្រតិបត្តិការ អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិ សន្តិសុខលម្ហសមុទ្រ

១៣-វរនាវីទោ **សូ ចន្ទ្រាបុត្រ** អត្តលេខ ០៤៨៤៩៤ ប្រធានការិយាល័យស្រាវជ្រាវច្បាប់ នាយកដ្ឋាននិតិកម្ម អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ

១៤-វរនាវីទោ **យ៉ន សុខហួរ** អត្តលេខ ០០៨៧៥២ ប្រធានការិយាល័យទំនាក់ទំនងសាធារណៈ នាយកដ្ឋាននិតិកម្ម អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ

១៥-វរនាវីទោ **ទៀ ដារ៉ា** អត្តលេខ ០៣១០១១ មេបញ្ជាការ កងនាវាអន្តរាគមន៍ ទីបញ្ជាការជួរមុខ អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ

១៦-វរនាវីទោ **ទៀ ណារិន** អត្តលេខ ០៥៥៨៨៦ ជំនួយការ ឯកឧត្តម អគ្គលេខាធិការ អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ

១៧-វរនាវីទោ **អ៊ូ ច័ន្ទណាន្ត** អត្តលេខ ០១៤៩៨៣ ជំនួយការ ឯកឧត្តម អគ្គលេខាធិការ អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ

១៨-វរនាវីទោ **គេច គីស៊ាន** អត្តលេខ ០៣០៤៤៩ ជំនួយការ ឯកឧត្តម មេបញ្ជាការ បញ្ជាការដ្ឋានកងទ័ពជើងទឹក

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងមុខតំណែងនាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ចំនួន ០២រូប ជាទីប្រឹក្សា សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយករងបន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលយកប្រាក់បៀវត្សរ៍

១-លោកឧត្តមសេនីយ៍ត្រី **ថូ ស្រេង** អត្តលេខ ០៩៧៨

២-លោកស្រីឧត្តមសេនីយ៍ត្រី **ឌិន នារី** អត្តលេខ ០៤៧៨៨។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការបញ្ចប់មុខតំណែងមន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៨៥ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការបង្កើតខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល
- យោងតាមតម្រូវការការងារចាំបាច់

### សម្រេច

**មាត្រា ១.-** បញ្ចប់មុខតំណែងលោក **ម៉ិន សារិទ្ធ** ពីជំនួយការឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានឋានៈស្មើ អគ្គនាយករង ។

**មាត្រា ២.-** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែមករា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...១៤...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១.**_បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន០៩រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងឧបដ្ឋានសាលា ០១ខ្នង មានបណ្តោយប្រវែង ២៩ម៉ែត្រ និងទទឹង១៧ម៉ែត្រ និងចាក់ដីសម្អាតទីធ្លាវត្តសាសនៈរង្សី (ហៅវត្តថែងគូក) ស្ថិតនៅភូមិអំពិល ឃុំព្រះស្តេច ខេត្តព្រៃវែង កន្លង ដូចមានរាយព្រះនាម និងនាមខាងក្រោម ៖

**ក-មេដាយប្រាក់ស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១-ភិក្ខុតុដ្ឋចិត្តោ | ហ៊ាប ហ៊ិន | ព្រះចៅអធិការវត្តសាសនៈរង្សី | បច្ច័យចំនួន៥.២០០ ដុល្លារ |
| ២-លោក | ហ្វូត យ៉ុន | អាចារ្យវត្តសាសនៈរង្សី | ថវិកាចំនួន ៥.០០០ ដុល្លារ |

**ខ-មេដាយសំរឹទ្ធស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១-លោក | ហ៊ាន់ សាក់ | អនុប្រធានអាចារ្យវត្តសាសនៈរង្សី | |
| ២-លោក | ហ៊ីន ហ៊ាន | សប្បុរសជនភូមិមុន្នីសិលា ខេត្តព្រៃវែង | ថវិកាចំនួន ៤.៦០០ ដុល្លារ |
| ៣-លោក | ចាន់ អេង | សប្បុរសជនភូមិអន្លង់ចារ ខេត្តព្រៃវែង | ថវិកាចំនួន ៤.៦០០ ដុល្លារ |
| ៤-លោក | ផន សារុន | គណៈកម្មការវត្តសាសនៈរង្សី | ថវិកាចំនួន ៣.៥០០ ដុល្លារ |
| ៥-លោក | ប្រាក់ សុខន់ | គណៈកម្មការវត្តសាសនៈរង្សី | ថវិកាចំនួន ៣.៥០០ ដុល្លារ |
| ៦-លោក | ឡេត ហ៊ុល | ប្រធានសាងសង់វត្តសាសនៈរង្សី | ថវិកាចំនួន ៣.០០០ ដុល្លារ |
| ៧-លោក | ហ៊ុំ ឆេន | អនុប្រធានសាងសង់វត្តសាសនៈរង្សី | ថវិកាចំនួន ៣.០០០ ដុល្លារ |

**មាត្រា២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ប្រធានអគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៥.អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

**មាត្រា១.**.បំពាក់មេដាយសហមេត្រី តាមលំដាប់ថ្នាក់ ជូនមន្ត្រីនៃអង្គការមិត្តនៃវប្បធម៌ខ្មែរ ចំនួន១០រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ព្រមទាំងបានគៀងគរជំនួយជាច្រើន ជួយដល់ការងារវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយ សហមេត្រី ថ្នាក់ ធិបឌិន្ទ**

| | | |
|---|---|---|
| ១- **ហេឡែន អ៊ីប៊ីតសុន យេស៊ុប** | ( Helen Ibbitson Jessup) | President |
| ២- **យ៉យ ក្លាក** | ( Joyce H. Clark ) | Vice President |

**ខ-មេដាយ សហមេត្រី ថ្នាក់ សេនា**

| | | |
|---|---|---|
| ១- **ខូនី បាហឺ** | ( Connie Baher ) | Vice President |
| ២- **ឆាល ប៊ិកហ្វត** | ( Charles G. Bickford ) | Vice President |
| ៣- **ដេវីត ឆែនឌ្លឺ** | ( David P . Chandler ) | Vice President |
| ៤- **ណេរ៉ូ ឆេង** | ( Nerou Cheng ) | Treasurer |
| ៥- **យែសហ្វ្រី គុណរាដ** | ( Jeffrey P. Cunard ) | Secretary |
| ៦- **អេង រ៉ូឡង់** | ( H.E Roland Eng ) | Vice President |
| ៧- **ម៉ៃខឹល ដឺហាវើណន់** | ( Michael de Havenon ) | Vice President |
| ៨- **ជែនី ស្ពែនខេក** | ( Jenny Spancake ) | Vice President |

**មាត្រា២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...០១...សសរ.

**សេចក្តីសម្រេច**

**ស្តីពី**

**ការបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិ**
**ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធី**
**នយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ១.** –

ត្រូវបានបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តបាត់ដំបង និង ខេត្តពោធិ៍សាត់ដូចខាងក្រោម៖

**១-ខេត្តបាត់ដំបង**

| | | |
|---|---|---|
| ១-ឯកឧត្តម **ជា ម៉ុង** | ទីប្រឹក្សាក្រសួងមហាផ្ទៃ | ជាសមាជិក |
| ២-ឯកឧត្តម **ឡាយ វ៉ាហារិទ្ធ** | ទីប្រឹក្សាក្រសួងមហាផ្ទៃ | ជាសមាជិក |

**២-ខេត្តពោធិ៍សាត់**

| | | |
|---|---|---|
| ១-ឯកឧត្តម **កែវ សែន** | ទីប្រឹក្សាក្រសួងមហាផ្ទៃ | ជាសមាជិក |

**ប្រការ២.** –

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០១៦

**តប.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**សម្តេចក្រឡាហោម ស ខេង**

<u>កន្លែងទទួល:</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៧ សសរ

## សេចក្ដីសម្រេច

## ស្ដីពី

## ការលុបចោលប័ណ្ណបើកបរប្រភេទ ក១

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១១៥/០០១ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការដោះស្រាយសំណូមពរដ៏ទទូចនិងសេចក្ដីត្រូវការចាំបាច់របស់ប្រជាជន

**សម្រេច**

**ប្រការ ១.-** លុបចោលប័ណ្ណបើកបរប្រភេទ **ក១** មានន័យថា អ្នកបើកបរទោចក្រយានយន្តដែលមានកម្លាំងចាប់ពី ១២៥ CC ចុះក្រោម មិនចាំបាច់មានប័ណ្ណបើកបរទៀតទេ ។

**ប្រការ ២.-** ប្រគល់ភារកិច្ចជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដឹកនាំការងាររៀបចំធ្វើវិសោធនកម្មជាបន្ទាន់ លើបទ-បញ្ញត្តិច្បាប់ដែលមានការពាក់ព័ន្ធសម្រាប់ដាក់ឆ្លងគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច ដើម្បីបញ្ជូនទៅស្ថាប័ននីតិបញ្ញត្តិពិនិត្យ និងផ្តល់ការអនុម័តជាកិច្ចការប្រញាប់ ។

**ប្រការ ៣.-** ក្រសួងមហាផ្ទៃ និងក្រសួងសាធារណការនិងដឹកជញ្ជូនត្រូវចាត់ចែងបង្កើនយុទ្ធនាការផ្សព្វផ្សាយ និងបង្រៀនច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឱ្យបានទូលំទូលាយជូនដល់សាធារណជន ជាពិសេសតាមរយៈស្ថានីយ៍វិទ្យុ ទូរទស្សន៍ និងផ្ទាំងប៉ាណូរូបភាពតាមទីសាធារណៈដើម្បីបង្កើនការយល់ដឹងអំពីច្បាប់ចរាចរណ៍ ក៏ដូចជាលើកស្ទួយការគោរពច្បាប់ចរាចរណ៍ និងលើកកម្ពស់សុវត្ថិភាពរបស់ប្រជាពលរដ្ឋក្នុងការធ្វើចរាចរណ៍ផ្លូវគោក ។

**ប្រការ ៤.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី* **០៦** *ខែ មករា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល:</u>**

*- ក្រសួងព្រះបរមរាជវាំង*

*- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*

*- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*- អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*

*- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*

*- ខុទ្ទកាល័យសម្តេច ឯកឧត្តម/ លោកជំទាវឧបនាយករដ្ឋមន្ត្រី*

*- ដូចប្រការ ៤*

*- រាជកិច្ច*

*- ឯកសារ- កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:..០៣...សសរ

សេចក្តីសម្រេច

ស្តីពី

សេចក្តីណែនាំស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមការងារបច្ចេកទេសចម្រុះ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣/ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៤៨៦ អនក្រ/បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- តាមសំណើរបស់ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាអនុប្រធានទី ១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**ប្រការ ១ .-**

ដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីបង្កើនប្រសិទ្ធភាពការងារ, ពង្រឹងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល និងបង្កើនប្រសិទ្ធភាពនៃភាពជាដៃគូ រវាងរាជរដ្ឋាភិបាល និងតួអង្គអភិវឌ្ឍន៍ ។

**ប្រការ ២ .-**

ក្រុមការងារបច្ចេកទេសចម្រុះ គឺជាយន្តការសម្របសម្រួល, ពិគ្រោះយោបល់ និងគាំទ្រដល់ការអនុវត្តផែនការ និងយុទ្ធសាស្ត្រតាមវិស័យ និងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ដើម្បីឈានទៅអនុវត្តឱ្យបានសម្រេចនូវគោលដៅអភិវឌ្ឍន៍ ។

**ប្រការ ៣ .-**

ក្រុមការងារបច្ចេកទេសចម្រុះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រធានក្រសួង ឬស្ថាប័ន ។ ប្រធានក្រសួង ឬស្ថាប័ន ត្រូវមានគណនេយ្យភាពចំពោះមុខរាជរដ្ឋាភិបាល ក្នុងការសម្រេចឱ្យបានលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ ស្របតាមគោលដៅអភិវឌ្ឍន៍ជាតិ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការតាមវិស័យ និងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ។

**ប្រការ ៤ .-**

ក្រុមការងារបច្ចេកទេសចម្រុះ ត្រូវប្រើប្រាស់សេចក្តីណែនាំនេះ ដើម្បីពង្រឹងការងាររបស់ខ្លួន តាមរយៈការរៀបចំលក្ខខ័ណ្ឌយោង និងការកំណត់របៀបរបបធ្វើការដែលសមស្របនឹងស្ថានភាពជាក់ស្តែងរបស់ក្រុមការងារខ្លួន ក៏ដូចជាការរៀបចំកម្មវិធីការងារដែលឆ្លើយតបនឹងអាទិភាពការងារបច្ចុប្បន្ន ដោយត្រូវពិភាក្សាជាមួយនឹងសមាជិកនៃក្រុមការងារ និងប្រធានសម្របសម្រួលរបស់ដៃគូអភិវឌ្ឍន៍ ។

**ប្រការ ៥ .-**

គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវផ្តល់ការគាំទ្របច្ចេកទេស តាមសំណើរបស់ប្រធានក្រុមការងារបច្ចេកទេសចម្រុះ ។

**ប្រការ ៦ .-**

ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាអនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ, ប្រធាន និងសមាជិកក្រុមការងារបច្ចេកទេសចម្រុះ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

# សេចក្តីណែនាំ
# ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារបច្ចេកទេសចម្រុះ

## ផ្នែកទី ១ : សាវតា បរិការណ៍ និងគោលបំណងនៃសេចក្តីណែនាំ

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតក្រុមការងារបច្ចេកទេសចម្រុះ ក្នុងឆ្នាំ ២០០៤ សម្រាប់ជាយន្តការក្នុងការសម្របសម្រួល និងពិគ្រោះយោបល់ ។ តំណាងក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល បានចូលរួមបំពេញការងារក្នុងយន្តការនេះ ដើម្បីឈានទៅអនុវត្តឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាតិ ដែលបានចែងក្នុងយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រតាមវិស័យ និងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ។ ផ្អែកតាមសេចក្តីណែនាំស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារបច្ចេកទេសចម្រុះ ដែលរាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនៅឆ្នាំ ២០១០ រហូតមកដល់បច្ចុប្បន្ន ក្រុមការងារបច្ចេកទេសចំនួន ១៩ បាន និងកំពុងបំពេញការងាររបស់ខ្លួននៅតាមវិស័យ និងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ។

គោលដៅចម្បងរបស់ក្រុមការងារបច្ចេកទេសចម្រុះ គឺគាំទ្រដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បី÷(១) អនុវត្តផែនការតាមវិស័យ និងការដ្ឋានកែទម្រង់ (២) កៀរគរ និងសម្របសម្រួលការប្រើប្រាស់ធនធានទាំងអស់ និង (៣) សម្រេចឱ្យបាននូវលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ ក្នុងគោលដៅគ្រប់គ្រងធនធានទាំងអស់ ដើម្បីឈានទៅសម្រេចនូវអាទិភាពដែលមានចែងក្នុងយុទ្ធសាស្ត្រ និងផែនការជាតិ និងតាមវិស័យ ។ លើមូលដ្ឋាននេះ ក្រុមការងារបច្ចេកទេសចម្រុះត្រូវបំពេញតួនាទីជាអ្នកផ្តល់ការគាំទ្រ និងជាអ្នកសម្របសម្រួល ហើយមិនត្រូវធ្វើការជំនួស ឬបំពេញមុខងារជាន់គ្នាជាមួយក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាលឡើយ ។

ដើម្បីបន្តជំរុញប្រសិទ្ធភាពឱ្យកាន់តែខ្ពស់ ក្រុមការងារបច្ចេកទេសចម្រុះនីមួយៗត្រូវពិនិត្យ និងកែសម្រួលជាប្រចាំអំពីរបៀបរបបស្តីពីភាពជាដៃគូ ដើម្បីគាំទ្រដល់រាជរដ្ឋាភិបាលក្នុងការសម្រេចនូវលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ ។ ការពិនិត្យឡើងវិញអំពីប្រសិទ្ធភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះ ដែលបានបញ្ចប់នាដើមឆ្នាំ ២០១៥ បានរំលេចអំពីឧត្តមានុវត្តន៍ និងបញ្ហាប្រឈមមួយចំនួន ដែលជះឥទ្ធិពលដល់លទ្ធភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះ ក្នុងការសម្រេចគោលដៅទាំងនេះ ។ បញ្ហាប្រឈមទាំងនោះរួមមាន ភាពចាំបាច់ក្នុងការកែសម្រួលឱ្យស្របទៅនឹងការប្រែប្រួលបរិស្ថាននៃភាពជាដៃគូ គួបផ្សំជាមួយបញ្ហាដែលពាក់ព័ន្ធនឹងការគ្រប់គ្រង ភាពជាអ្នកដឹកនាំ រចនាសម្ព័ន្ធស្ថាប័ន និងរបៀបអនុវត្តការងារ ។ ម្យ៉ាងវិញទៀត ក្នុងពេលដែលសេដ្ឋកិច្ចកម្ពុជាកំពុងអភិវឌ្ឍយ៉ាងលឿន ដើម្បីឈានទៅសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប បរិការណ៍កម្ពុជា និងបរិការណ៍តាមវិស័យសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ក៏មានភាពប្រែប្រួលផងដែរ ។ ទន្ទឹមនឹងនេះ ក្នុងពេលដែលរាជរដ្ឋាភិបាលប្រមូលធនធានក្នុងស្រុកបានកាន់តែច្រើនឡើងៗ ហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការ កំពុងត្រូវបានផ្ទេរពីហិរញ្ញប្បទានឥតសំណងទៅជាឥណទានសម្បទាន ទន្ទឹមនឹងពេលដែលកម្ពុជាមានប្រភពហិរញ្ញប្បទានជាច្រើនពីក្រៅប្រទេស និងមានដៃគូអភិវឌ្ឍន៍ថ្មីៗបន្ថែមទៀត ហើយដែលដៃគូមួយចំនួនមិនទាន់បានចូលរួមក្នុងក្រុមការងារនៅឡើយ ។ លើសពីនេះ កម្ពុជាកំពុងជួបប្រទះនឹងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍ដែលមានលក្ខណៈកាន់តែស្មុគស្មាញឡើងៗ ហើយដែលតម្រូវឱ្យមានកិច្ចសហការល្អរវាងបណ្តាវិស័យពាក់ព័ន្ធ ។

គោលបំណងនៃសេចក្តីណែនាំនេះ គឺបង្កើនប្រសិទ្ធភាពនៃការអនុវត្តការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះ តាមរយៈការពង្រឹងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល និងការបង្កើនប្រសិទ្ធភាពនៃភាពជាដៃគូ ។ សេចក្តីណែនាំបាន កំណត់អំពីរចនាសម្ព័ន្ធស្តីពីគណនេយ្យភាព និងរបៀបអនុវត្តការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះ ហើយក៏ជា ឧបករណ៍សម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ ២០១៤-២០១៨ ផងដែរ ។

រាជរដ្ឋាភិបាលជំរុញលើកទឹកចិត្តឱ្យក្រុមការងារបច្ចេកទេសចម្រុះប្រើប្រាស់សេចក្តីណែនាំនេះ ដើម្បីពង្រឹងការងារ របស់ខ្លួន រួមមាន ÷ ការរៀបចំលក្ខខ័ណ្ឌយោងឱ្យស្របនឹងក្រុមការងាររបស់ខ្លួន ការរៀបចំកម្មវិធីការងារដែលឆ្លើយតប នឹងអាទិភាពការងារបច្ចុប្បន្ន និងការកំណត់របៀបរបបធ្វើការដែលសមស្របនឹងស្ថានភាពជាក់ស្តែងរបស់ក្រុមការងារ ។ សេចក្តីណែនាំនេះក៏បានរំលេចអំពីតួនាទីរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការគាំទ្រក្រុមការងារទាំងអស់ ដោយផ្អែក តាមសំណើរបស់ប្រធានក្រុមការងារនីមួយៗ ។

**ផ្នែកទី ២ : គណនេយ្យភាព តួនាទី និងភារកិច្ចរបស់ក្រុមការងារបច្ចេកទេសចម្រុះ**

ក្រុមការងារបច្ចេកទេសចម្រុះ គឺជាយន្តការសម្រាប់សម្របសម្រួល ពិគ្រោះយោបល់ និងគាំទ្រដល់ការអនុវត្ត កម្មវិធីតាមវិស័យ និងកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ។ ក្នុងស្មារតីនេះ ក្រុមការងារបច្ចេកទេសចម្រុះត្រូវ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ឬស្ថាប័នសាមី ដែលត្រូវមានគណនេយ្យភាពក្នុងការសម្រេចឱ្យបានលទ្ធផល នៃកិច្ចអភិវឌ្ឍន៍ ស្របតាមអាទិភាពដែលមានចែងក្នុងផែនការជាតិ និងផែនការរបស់វិស័យ ។ ផ្អែកតាមគោលការណ៍ស្តីពី ភាពជាម្ចាស់ ប្រធានក្រុមការងារបច្ចេកទេសចម្រុះដែលជាតំណាងរបស់រាជរដ្ឋាភិបាល គឺជាអ្នកមានសិទ្ធិសម្រេចចុង ក្រោយលើរាល់កិច្ចការរបស់ក្រុមការងារបច្ចេកទេសចម្រុះ ។ ទន្ទឹមនឹងនេះ ប្រធានក្រុមការងារក៏ត្រូវខិតខំជំរុញឱ្យមានកិច្ច ពិភាក្សា និងការឯកភាពរួមគ្នា ដោយឈរលើស្មារតីភាពជាដៃគូ ដែលជាគោលការណ៍ស្នូលក្នុងការអនុវត្តការងាររបស់ ក្រុមការងារបច្ចេកទេសចម្រុះ ។

ដៃគូអភិវឌ្ឍន៍ត្រូវអនុវត្តការងារ ដោយសហការជាមួយក្រសួង និងស្ថាប័នរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដទៃទៀត ដើម្បីតម្រឹមធនធាន និងតម្រង់ទិសកិច្ចប្រឹងប្រែងរបស់ខ្លួន ក្នុងគោលដៅឈានទៅសម្រេចគោលដៅ និង លទ្ធផល ដែលមានចែងក្នុងយុទ្ធសាស្ត្រ និងផែនការជាតិ និងផែនការវិស័យ ។ ដៃគូអភិវឌ្ឍន៍នីមួយៗអាចចូលរួមចំណែក ដោយផ្ទាល់ ឬតាមរយៈប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ ក្នុងកិច្ចការរបស់ក្រុមការងារបច្ចេកទេសចម្រុះ ស្របតាម តួនាទី និងភារកិច្ចដែលបានកំណត់ក្នុងសេចក្តីណែនាំនេះ ។

ក្រុមការងារបច្ចេកទេសចម្រុះត្រូវរាយការណ៍ជូនក្រសួង ឬស្ថាប័នសាមី អំពីវឌ្ឍនភាព និងបញ្ហាប្រឈមដែល ពាក់ព័ន្ធនឹងវិស័យរបស់ខ្លួន ក៏ដូចជាវឌ្ឍនភាពក្នុងការអនុវត្តសូចនាករតាមដានរួមគ្នា កម្មវិធីកែទម្រង់វិស័យសាធារណៈ និងបញ្ហាអន្តរវិស័យ ។ ក្រសួង ឬស្ថាប័នសាមីត្រូវដោះស្រាយបណ្តាបញ្ហាដែលមិនអាចដោះស្រាយនៅកម្រិតក្រុមការងារ បច្ចេកទេសចម្រុះ ។ ក្នុងករណីដែលមិនអាចដោះស្រាយក្នុងក្រុមការងារបច្ចេកទេសចម្រុះ ឬតាមរយៈយន្តការពិភាក្សា និងពិគ្រោះយោបល់ ដែលដឹកនាំដោយក្រសួង ឬស្ថាប័នសាមី បញ្ហាទាំងនោះអាចលើកទៅពិភាក្សានៅក្នុងកិច្ចប្រជុំរបស់ គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ។ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា

នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.ន/ក.អ.ក) មានភារៈកិច្ចរៀបចំកិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និងរៀបចំរបាយការណ៍សរុបស្តីពីវឌ្ឍនភាពនៃការអនុវត្តសូចនាករតាមដានរួមគ្នា ដោយពិភាក្សាជាមួយប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ និងដោយមានការគាំទ្របច្ចេកទេសពីប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍នៃក្រុមការងារបច្ចេកទេសចម្រុះស្តីពីភាពជាដៃគូ និងសុខដុមនីយកម្ម ។

សេចក្តីណែនាំនេះបានកំណត់អំពីតួនាទី និងភារកិច្ច ចំនួន ៦ ដែលក្រុមការងារបច្ចេកទេសចម្រុះត្រូវរំលេចក្នុងលក្ខខ័ណ្ឌយោង និងផែនការសកម្មភាពរបស់ខ្លួន ។ រីឯសកម្មភាពការងារលម្អិតសម្រាប់អនុវត្តតួនាទី និងភារកិច្ចទាំងនោះ គឺជាសមត្ថកិច្ចរបស់ក្រុមការងារនីមួយៗ ។ ទន្ទឹមនឹងនេះ ក៏ត្រូវកំណត់គោលការណ៍សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំ និងកំណត់លំដាប់អាទិភាពការងារ ដោយផ្អែកលើតម្រូវការដែលបានឯកភាព លទ្ធភាពធនធាន និងសមត្ថភាពរបស់ក្រុមការងារនីមួយៗ ។ លើសពីនេះ ក្រុមការងារនីមួយៗអាចបង្កើតអនុក្រុមការងារ សម្រាប់ពិនិត្យ និងតាមដានការងារដែលពាក់ព័ន្ធនឹងប្រធានបទ ឬបញ្ហាជាក់លាក់ ។

ក្រុមការងារបច្ចេកទេសចម្រុះត្រូវកំណត់អំពីវិសាលភាពការងាររបស់ខ្លួន ដោយផ្អែកលើរបកគំហើញទាំង ៦ ដែលបានរំលេចក្នុងរបាយការណ៍ស្តីពីការពិនិត្យលទ្ធផលក្នុងការអនុវត្តការងាររបស់ក្រុមការងារ ឆ្នាំ ២០១៤-២០១៥ ។ បន្ទាប់ពីបានជ្រើសរើសរួច ក្រុមការងារត្រូវរំលេច ទៅក្នុងលក្ខខ័ណ្ឌយោង ហើយត្រូវរៀបចំសកម្មភាពការងារ ដើម្បីបញ្ចូលទៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ។ សកម្មភាពអាទិភាពទាំងនេះក៏ត្រូវរំលេចទៅក្នុងសូចនាករតាមដានរួមគ្នារបស់ក្រុមការងារបច្ចេកទេសចម្រុះផងដែរ ។

### ***១- ការតម្រឹម ការសម្របសម្រួល ការកៀរគរ និងការប្រើប្រាស់ធនធាន***

ការសម្របសម្រួល និងការកៀរគរធនធាន គឺជាភារកិច្ចស្នូលរបស់ក្រុមការងារបច្ចេកទេសចម្រុះ ។ យុទ្ធសាស្រ្តស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ បានកំណត់គោលការណ៍ អភិក្រម និងឧបករណ៍ សម្រាប់ពង្រឹងភាពជាដៃគូ ។ លើមូលដ្ឋាននេះ ក្រុមការងារបច្ចេកទេសចម្រុះត្រូវអនុវត្តកិច្ចការរបស់ខ្លួន ដើម្បី ÷

ក- ធានាការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការ ជាមួយអាទិភាពជាតិ និងយុទ្ធសាស្រ្តរបស់វិស័យ ។

ខ- ជំរុញការអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងទម្រង់ផ្តល់ហិរញ្ញប្បទានសមស្របដទៃទៀត សម្រាប់គាំទ្រការរៀបចំ និងការអនុវត្តយុទ្ធសាស្រ្តតាមវិស័យ ការធ្វើហិរញ្ញប្បទាន និងការតាមដាន ព្រមទាំងការពិនិត្យឡើងវិញនូវយុទ្ធសាស្រ្តតាមវិស័យ ។

គ- កត់ត្រាព័ត៌មាននានាពាក់ព័ន្ធនឹងគម្រោងរបស់ដៃគូអភិវឌ្ឍន៍ដែលកំពុងដំណើរការ ទៅក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ និងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានរបស់អង្គការមិនមែនរដ្ឋាភិបាល (http://cdc.khmer.biz) ព្រមទាំងប្រើប្រាស់ព័ត៌មានទាំងនោះ ដើម្បីសម្របសម្រួលការងារ ។

ឃ- កំណត់ទំហំធនធានដែលត្រូវកៀរគរបន្ថែម និងគម្រោងដែលត្រៀមអនុវត្ត ដើម្បីឆ្លើយតបនឹងសកម្មភាពអាទិភាពនៃផែនការ ឬយុទ្ធសាស្រ្តតាមវិស័យ ។

ង- គាំទ្រការរៀបចំកម្មវិធីវិនិយោគសាធារណៈ និងផែនការយុទ្ធសាស្រ្តថវិកាតាមវិស័យ ។

### ២- កិច្ចពិគ្រោះយោបល់កម្រិតគោលនយោបាយ

កិច្ចពិគ្រោះយោបល់នេះត្រូវផ្តោតលើការរៀបចំ និងការអនុវត្តយុទ្ធសាស្ត្រ ឬផែនការតាមវិស័យ ដែលមានសង្គតិភាពជាមួយនឹងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ក្រុមការងារបច្ចេកទេសចម្រុះគប្បីផ្តោតលើការងារមួយចំនួនដូចខាងក្រោម ÷

ក- កំណត់បណ្តាអាទិភាពនៅតាមវិស័យ និងរៀបចំ និងអនុវត្តយុទ្ធសាស្ត្រតាមវិស័យ ដែលមានសង្គតិភាពជាមួយយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងបញ្ហាអន្តរវិស័យ និងការកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ។ ទន្ទឹមនឹងនេះ ក៏ត្រូវយកចិត្តទុកដាក់លើតម្រូវការក្នុងការអភិវឌ្ឍសមត្ថភាពរបស់ក្រុមការងារ និងការពង្រឹង និងការប្រើប្រាស់ប្រព័ន្ធជាតិ ។

ខ- រៀបចំកម្មវិធីប្រចាំឆ្នាំសម្រាប់កិច្ចពិគ្រោះយោបល់កម្រិតគោលនយោបាយ ឬដើម្បីពិនិត្យលទ្ធផលការងារ ។ ក្នុងករណីចាំបាច់ ការងារនេះអាចរៀបចំតាមរយៈអនុក្រុមការងារ ។

គ- ពិភាក្សា ឬ ធ្វើបច្ចុប្បន្នភាពគំនិតផ្តួចផ្តើមថ្មីៗស្តីពីគោលនយោបាយដែលពាក់ព័ន្ធនឹងការងាររបស់សមាជិកក្រុមការងារ ព្រមទាំងពិនិត្យភាពប្រទាក់ក្រឡា ឬភាពបំពេញឱ្យគ្នាទៅវិញទៅមក រវាងគោលនយោបាយទាំងនោះ ។

ឃ- ជំរុញកិច្ចពិគ្រោះយោបល់លើការអនុវត្តគោលនយោបាយ (វឌ្ឍនភាព និងបញ្ហាប្រឈម) សម្រាប់រៀនសូត្រ និងដកបទពិសោធន៍ ព្រមទាំងកែតម្រូវ ។

ង- ផ្តោតការយកចិត្តទុកដាក់លើកម្មវិធីកែទម្រង់ បញ្ហាអន្តរវិស័យ និងការងារដទៃទៀត ដែលតម្រូវឱ្យមានកិច្ចសហការរវាងបណ្តាក្រសួង ឬស្ថាប័នរបស់រាជរដ្ឋាភិបាល ដើម្បីកំណត់កាលានុវត្តភាពសម្រាប់កិច្ចសហការ និងកិច្ចពិភាក្សា ដែលអាចផ្តល់អត្ថប្រយោជន៍ដល់គ្រប់ភាគីពាក់ព័ន្ធ ។

### ៣- បញ្ហាអន្តរវិស័យ

ក្រុមការងារបច្ចេកទេសចម្រុះត្រូវផ្តោតការងារជាសំខាន់ ទៅលើវិស័យ ឬការដ្ឋានកែទម្រង់ ឬប្រធានបទជាក់លាក់ ដែលពាក់ព័ន្ធនឹងអាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ទន្ទឹមនឹងនេះ ក៏ត្រូវផ្តោតលើបញ្ហាអន្តរវិស័យដែលក្រុមការងារបច្ចេកទេសចម្រុះអាចផ្តល់ការគាំទ្រ តាមរយៈការអនុវត្តសកម្មភាពនៅក្នុងវិស័យរបស់ខ្លួន ឬតាមរយៈកិច្ចសហការជាមួយបណ្តាក្រសួង និងស្ថាប័នរបស់រាជរដ្ឋាភិបាល ឬក្រុមការងារដទៃទៀត ។ ដើម្បីឆ្លើយតបនឹងអាទិភាពដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ ក្រុមការងារបច្ចេកទេសចម្រុះត្រូវផ្តោតលើបញ្ហាអន្តរវិស័យសំខាន់ៗ ដូចជា ÷ ការបញ្ជ្រាបយេនឌ័រ បរិស្ថាន និងបម្រែបម្រួលអាកាសធាតុ និងអភិបាលកិច្ចល្អ ដែលរួមមានការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាជន ។

ដើម្បីដោះស្រាយបញ្ហាអន្តរវិស័យ ក្រុមការងារបច្ចេកទេសចម្រុះគប្បីអនុវត្តដូចខាងក្រោម ÷

ក- សមាជិកភាពរបស់ក្រុមការងារត្រូវមានសង្គតិភាពជាមួយបញ្ហាអន្តរវិស័យដែលត្រូវពិភាក្សា ។

ខ- ពិនិត្យលទ្ធភាពបង្កើតអនុក្រុមការងារ ដើម្បីពិនិត្យ និងដោះស្រាយបញ្ហាអន្តរវិស័យ ។ អនុក្រុមការងារត្រូវរាយការណ៍អំពីលទ្ធផលការងាររបស់ខ្លួន ជូនក្រុមការងារបច្ចេកទេសចម្រុះ ។

គ- អាចចាត់តាំងមន្ត្រីបង្គោលរបស់ស្ថាប័នសាមុី ឱ្យទទួលខុសត្រូវ និងគ្រប់គ្រងបញ្ហាអន្តរវិស័យដែលពាក់ព័ន្ធនឹងក្រុមការងាររបស់ខ្លួន ។

ឃ- ពិនិត្យ និងរៀបចំកិច្ចប្រជុំរវាងសមាជិកស្នូលនៃបណ្តាក្រុមការងារពាក់ព័ន្ធ ដើម្បីធានាសង្គតិភាព និងជំរុញការតាមដាន ។

ង- កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ នឹងផ្តល់កាលានុវត្តភាពបន្ថែមសម្រាប់កិច្ចសម្របសម្រួលអន្តរក្រសួង  និងសម្រាប់ពង្រឹងទំនាក់ទំនង  និងដោះស្រាយបញ្ហាប្រឈមអន្តរវិស័យ ដែលបានរំលេចក្នុងរបាយការណ៍របស់ក្រុមការងារ ។

### ៤- ការអភិវឌ្ឍសមត្ថភាព និងការពង្រឹងស្ថាប័ន

សកម្មភាពសម្រាប់អភិវឌ្ឍសមត្ថភាពត្រូវអនុវត្តក្នុងបរិការណ៍នៃការកែទម្រង់វិស័យសាធារណៈ ហើយត្រូវផ្តោតលើការពង្រឹងសមត្ថភាពស្ថាប័ន  ការប្រើប្រាស់ប្រព័ន្ធជាតិ  និងការបង្កើនមុខជំនាញ  ។  ដើម្បីបង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍសមត្ថភាព ក្រុមការងារបច្ចេកទេសចម្រុះគួរអនុវត្តការងារដូចខាងក្រោម ÷

ក- រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពប្រកបដោយភាពប្រទាក់ក្រឡា ដោយផ្អែកលើការវាយតម្លៃអំពីតម្រូវការជាក់ស្តែង និងការពិនិត្យឡើងវិញអំពីតួនាទី និងភារកិច្ច ដើម្បីអភិវឌ្ឍសមត្ថភាពខាងគោលនយោបាយ និងខាងស្ថាប័ន ក៏ដូចជាអភិវឌ្ឍសមត្ថភាពរបស់មន្ត្រី ។

ខ- កំណត់ និងឯកភាពលើកម្មវិធី ឬគម្រោងស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស ក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍសមត្ថភាពតាមវិស័យ  ដោយផ្អែកលើសេចក្តីណែនាំស្តីពីការផ្តល់  និងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការបច្ចេកទេស ដើម្បីជំរុញការប្រើប្រាស់ឧត្តមានុវត្តន៍ ។

គ- រៀបចំសូចនាករ និងតាមដានការអនុវត្ត ដើម្បីវាយតម្លៃវឌ្ឍនភាពក្នុងការអភិវឌ្ឍសមត្ថភាព ។ ទន្ទឹមនេះការពិនិត្យឡើងវិញអំពីគោលនយោបាយ និងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ  ពិសេស ពាក់ព័ន្ធនឹងការកែទម្រង់វិស័យសាធារណៈ ត្រូវរំលេចអំពីបញ្ហាប្រឈមខាងសមត្ថភាព និងតម្រូវការក្នុងការអភិវឌ្ឍសមត្ថភាពផងដែរ ។

### ៥- ការចែករំលែកព័ត៌មាន

ការចែករំលែកព័ត៌មានដើម្បីសមាជិកក្រុមការងារបច្ចេកទេសចម្រុះទាំងអស់អាចបំពេញភារកិច្ច ជាបុគ្គល និងជាក្រុម គឺជាភារកិច្ចអប្បបរមារបស់ក្រុមការងារបច្ចេកទេសចម្រុះ ។ ក្រុមការងារគប្បីបំពេញការងារដូចខាងក្រោម ÷

ក- ក្រុមការងារបច្ចេកទេសចម្រុះ គឺជាវេទិកាសម្រាប់ចែករំលែកព័ត៌មានស្តីពីកិច្ចការដែលកំពុងអនុវត្ត ហើយដែលពាក់ព័ន្ធនឹងភារកិច្ចរបស់ក្រុមការងារ (ដូចជា ការសិក្សាស្រាវជ្រាវ បេសកកម្ម និងការត្រួតពិនិត្យ) ។

ខ- ផ្តល់ព័ត៌មានដល់សមាជិកគ្រប់រូប អំពីកិច្ចប្រជុំ ឬកិច្ចពិគ្រោះយោបល់ ពិសេស ពាក់ព័ន្ធនឹងការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ដល់ក្រុមការងារ ។

គ- ផ្តល់ព័ត៌មានបច្ចុប្បន្នភាពដល់សមាជិកគ្រប់រូប អំពីការរៀបចំកម្មវិធី ឬការអនុវត្តការងារ ដែលជះឥទ្ធិពលដល់ការអនុវត្តគោលដៅរបស់ក្រុមការងារ ដូចមានចែងក្នុងលក្ខខ័ណ្ឌយោង និងផែនការប្រចាំឆ្នាំ ។

ឃ- ចែករំលែកព័ត៌មានស្តីពីសកម្មភាពរបស់តួអង្គអភិវឌ្ឍន៍ដទៃទៀត ដែលគាំទ្រដល់វិស័យ ឬការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះ (ដូចជា វិស័យឯកជន ដៃគូអភិវឌ្ឍន៍ដែលមិនមានវត្តមានក្នុងកម្ពុជា ឬដៃគូដែលមិនមែនជាសមាជិកនៃក្រុមការងារបច្ចេកទេសចម្រុះ) ។

ង- ពិនិត្យវិសាលភាព និងប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងព័ត៌មាន ដើម្បីឱ្យរាជរដ្ឋាភិបាល និងក្រុមការងារបច្ចេកទេសចម្រុះ អាចទទួលព័ត៌មានត្រឹមត្រូវ និងទាន់ពេលវេលា ។

ច- ជំរុញការចែករំលែកចំណេះដឹងតាមប្រព័ន្ធអនឡាញ នូវគោលនយោបាយ ផែនការ ច្បាប់ របាយការណ៍ ព្រមទាំងព័ត៌មាន និងទិន្នន័យដទៃទៀត ។

### ៦- *ការតាមដាន និងវាយតម្លៃវឌ្ឍនភាព*

ក្រុមការងារបច្ចេកទេសចម្រុះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួង ឬស្ថាប័នសាមី ហើយត្រូវរាយការណ៍ជូនក្រសួង ឬស្ថាប័នសាមី អំពីវឌ្ឍនភាព និងបញ្ហាប្រឈម ក្នុងការអនុវត្តផែនការការងារ ក៏ដូចជាការគាំទ្ររបស់ខ្លួន ក្នុងការឈានទៅសម្រេចលទ្ធផលរបស់វិស័យ ។ ទន្ទឹមនឹងនេះ ក៏ត្រូវរាយការណ៍អំពីវឌ្ឍនភាពក្នុងការអនុវត្តសូចនាករតាមដានរួមគ្នា កម្មវិធីកែទម្រង់វិស័យសាធារណៈ និងបញ្ហាអន្តរវិស័យ ។ ក្រុមការងារត្រូវវាយតម្លៃជាប្រចាំអំពីលទ្ធផលការងាររបស់ខ្លួន ដោយត្រូវរំលេចអំពីបញ្ហាប្រឈម ដើម្បីអនុវត្តឱ្យបានសម្រេចនូវគោលដៅអភិវឌ្ឍន៍ជាតិ និងគោលដៅតាមវិស័យ ព្រមទាំងសូចនាករតាមដានរួមគ្នា ។ ការរៀបចំកិច្ចប្រជុំ ឬអង្គវិបស្សនា សម្រាប់ពិនិត្យប្រសិទ្ធភាពនៃក្រុមការងារ ក៏ដូចជាដើម្បីត្រួតពិនិត្យវឌ្ឍនភាពក្នុងការអនុវត្តគោលដៅរបស់វិស័យ គឺជាកិច្ចការស្នូលរបស់ក្រុមការងារនីមួយៗ ។ ការពិនិត្យ និងការតាមដាននេះ ត្រូវផ្សារភ្ជាប់ជាមួយការអភិវឌ្ឍសមត្ថភាព ដើម្បីក្រុមការងារមានប្រព័ន្ធតាមដាន និងមានសមត្ថភាពគ្រប់គ្រាន់សម្រាប់វាយតម្លៃ ។ ក្រុមការងារគប្បីអនុវត្តការងារមួយចំនួនដូចខាងក្រោម ÷

ក- បញ្ជាក់ប្រភពទិន្នន័យ និងធ្វើសុពលភាពទិន្នន័យ សម្រាប់ជាមូលដ្ឋានក្នុងការតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការតាមវិស័យ ។ ទន្ទឹមនេះ ក៏ត្រូវកំណត់អំពីកិច្ចការដែលមានចរិតជាការវិភាគមួយចំនួនបន្ថែមទៀត ដែលក្រុមការងារអាចផ្តល់ការគាំទ្រ ដើម្បីពង្រឹងប្រព័ន្ធតាមដាន និងរបាយការណ៍ ។

ខ- ជំរុញការប្រើប្រាស់ក្របខ័ណ្ឌលទ្ធផលនៅកម្រិតវិស័យ និងតាមដានវឌ្ឍនភាពនៃសូចនាករតាមដានរួមគ្នា ដែលផ្សារភ្ជាប់នឹងគោលដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការតាមវិស័យ ។ ទន្ទឹមនឹងនេះ ត្រូវប្រើប្រាស់កិច្ចដំណើរការរបៀបនេះ និងក្របខ័ណ្ឌលទ្ធផល ដើម្បីជំរុញឱ្យមានកិច្ចពិគ្រោះយោបល់សម្រាប់វាយតម្លៃវឌ្ឍនភាព និងកំណត់អាទិភាពរបស់ក្រុមការងារ ។

គ- កំណត់ និងឯកភាពលើទម្រង់សមស្រប ដូចជា កិច្ចប្រជុំ ឬអង្គវិបស្សនាតាមកាលកំណត់ សម្រាប់ពិនិត្យ និងតាមដានវឌ្ឍនភាពរបស់ក្រុមការងារ ក៏ដូចជាវឌ្ឍនភាពរបស់វិស័យ ។

ឃ- ពិនិត្យ និងតាមដានបញ្ហានានាដែលបានលើកឡើងក្នុងវេទិកាដទៃទៀត ហើយដែលមានការពាក់ព័ន្ធនឹងកិច្ចការរបស់ក្រុមការងារ និងរបស់វិស័យ សម្រាប់ពិភាក្សាបន្តក្នុងក្រុមការងាររបស់ខ្លួន ។

ង- ពិនិត្យ និងពង្រឹងប្រព័ន្ធតាមដាន និងសមត្ថភាពនៃក្រសួងនិងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ។

**ផ្នែកទី ៣ : យន្តការស្ថាប័ន**

***១- សមាសភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះ***

ក្រុមការងារបច្ចេកទេសចម្រុះនីមួយៗត្រូវមានសមាជិកជាតំណាងរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ។ ប្រធានក្រុមការងារបច្ចេកទេសចម្រុះ ដោយពិភាក្សាជាមួយសមាជិកដែលមានបច្ចុប្បន្ន គឺជាអ្នកមានសិទ្ធិសម្រេចចុងក្រោយ លើសមាជិកភាពរបស់ក្រុមការងារ ។ ទន្ទឹមនឹងនេះ ដើម្បីធានាកិច្ចពិភាក្សាបានចំទិសដៅ ក្រុមការងារបច្ចេកទេសចម្រុះគួរយកចិត្តទុកដាក់លើបណ្តាចំណុចដូចខាងក្រោម ÷

ក- *ប្រធានក្រុមការងារបច្ចេកទេសចម្រុះតែងតាំងដោយរាជរដ្ឋាភិបាល* : ប្រធានក្រុមការងារត្រូវតែងតាំងដោយប្រធានស្ថាប័ន និងត្រូវបំពេញការងារជូនស្ថាប័នខ្លួន ។ ប្រធានក្រុមការងារត្រូវមានសមត្ថភាពដោះស្រាយបញ្ហានានារបស់ក្រុមការងារ និងត្រូវដឹកនាំកិច្ចពិភាក្សាឱ្យមានភាពរលូន ។ ទន្ទឹមនឹងនេះ ប្រធានក៏ត្រូវប្តេជ្ញាខ្ពស់ និងត្រូវទំនាក់ទំនង និងតាមដានវឌ្ឍនភាពការងារ ជាមួយក្រសួងនិងស្ថាប័នដទៃទៀតរបស់រាជរដ្ឋាភិបាលដែលមានតំណាងរបស់ខ្លួននៅក្នុងក្រុមការងារ ព្រមទាំងយល់ដឹងអំពីគម្រោង ឬកម្មវិធីដែលដៃគូអភិវឌ្ឍន៍កំពុងគាំទ្រក្នុងវិស័យរបស់ខ្លួន ។

ខ- *ប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍* : ប្រធានសម្របសម្រួលរបស់ដៃគូអភិវឌ្ឍន៍ គឺជាតំណាងជាន់ខ្ពស់នៃស្ថាប័ន ឬប្រទេសផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ ហើយត្រូវមានសមត្ថភាព និងជំនាញច្បាស់លាស់លើការងាររបស់វិស័យ និងមានឆន្ទៈក្នុងការចែករំលែកព័ត៌មានដល់ដៃគូអភិវឌ្ឍន៍ដទៃទៀត ។ ដៃគូអភិវឌ្ឍន៍ត្រូវកំណត់បែបបទសម្រាប់ជ្រើសតាំង ឬផ្លាស់ប្តូរប្រធានសម្របសម្រួល ។ ប៉ុន្តែ ដើម្បីធានាចីរភាពនៃការងារ ប្រធានសម្របសម្រួលអាចមានអាណត្តិកាលក្នុងក្រុមការងារ រយៈពេល ២ ឆ្នាំ យ៉ាងតិច ។

គ- *លេខាធិការដ្ឋានក្រុមការងារបច្ចេកទេសចម្រុះ* : ក្រសួង ឬស្ថាប័នសាម៉ីបង្កើតលេខាធិការដ្ឋានមួយ ដែលស្ថិតក្រោមការដឹកនាំផ្ទាល់របស់ប្រធានក្រុមការងារ ដើម្បីគាំទ្រកិច្ចការរដ្ឋបាលរបស់ក្រុមការងារ តាមដានវឌ្ឍនភាពនៃការអនុវត្តសកម្មភាពការងារដែលបានឯកភាពក្នុងកិច្ចប្រជុំរបស់ក្រុមការងារ និងជួយសម្របសម្រួលការគ្រប់គ្រងព័ត៌មាន ព្រមទាំងធ្វើជាតំណាងក្រុមការងាររបស់ខ្លួន នៅក្នុងក្រុមការងារបច្ចេកទេសចម្រុះស្តីពីភាពជាដៃគូ និងសុខដុមនីយកម្ម ។

ឃ- *តំណាងក្រសួង និងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល* : សមាជិកទាំងនេះត្រូវផ្តល់ការគាំទ្រដល់កិច្ចសម្របសម្រួលអន្តរស្ថាប័ន ពិសេសក្នុងការដ្ឋានកែទម្រង់ស្នូលនានារបស់រាជរដ្ឋាភិបាល ។ ទន្ទឹមនឹងនេះត្រូវមានសមត្ថភាព និងការយល់ដឹងខ្ពស់ខាងបច្ចេកទេស ព្រមទាំងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ធ្វើជាតំណាងឱ្យក្រសួង និងស្ថាប័ន ។ លើសពីនេះ ក៏ត្រូវមានសមត្ថភាពគ្រប់គ្រាន់ក្នុងការលើកទស្សនៈ និងបញ្ចេញមតិក្នុងនាមស្ថាប័នសាម៉ី ព្រមទាំងមានលទ្ធភាពក្នុងការផ្តល់ព័ត៌មាន ក៏ដូចជាក្នុងការសម្របសម្រួលតាមដានវឌ្ឍនភាពនៃការអនុវត្តសកម្មភាពការងារនៅក្នុងក្រសួង ឬស្ថាប័នរបស់ខ្លួន ។ សមាជិកដែលជា

តំណាងក្រសួងឬស្ថាប័ននីមួយៗ ត្រូវចែករំលែកព័ត៌មាន និងចំណេះដឹងរបស់ខ្លួន ក្នុងអង្គប្រជុំរបស់ក្រុមការងារ ហើយត្រូវពនៃព័ត៌មាន និងសកម្មភាពដែលត្រូវអនុវត្តបន្ត ជម្រាបជូនក្រសួង ឬស្ថាប័នសាមីវិញ ។

ង- *ដៃគូអភិវឌ្ឍន៍ដទៃទៀតដែលធ្វើការតាមវិស័យនីមួយៗ* : ដៃគូអភិវឌ្ឍន៍ដែលចូលរួមក្នុងក្រុមការងារ ត្រូវមានឋានៈ និងសមត្ថភាពសមស្រប និងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចែករំលែកព័ត៌មាន និងការផ្តល់ការគាំទ្រដល់ប្រធានក្រុមការងារ ក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា ។ ដៃគូអភិវឌ្ឍន៍ទាំងនេះត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធនឹងកម្មវិធី ឬកម្មវិធីដែលខ្លួនកំពុងគាំទ្រ ឬដែលគ្រោងផ្តល់ការគាំទ្រ ។ លើសពីនេះ ក៏ត្រូវចែករំលែកព័ត៌មានស្តីពីការពិភាក្សា និងការសម្រេចចិត្តរបស់ក្រុមការងារ ដល់ដៃគូអភិវឌ្ឍន៍ដទៃទៀតផងដែរ ។

ច- *មន្ត្រីបង្គោលនៃគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ. ជ. ន/ក. អ. ក)* : តំណាងរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គឺជាសមាជិករបស់ក្រុមការងារ សម្រាប់ផ្តល់ការគាំទ្រនានាដែលពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងប្រសិទ្ធភាពនៃកិច្ចអភិវឌ្ឍន៍ ដូចបានរំលេចក្នុងយុទ្ធសាស្ត្រ ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ។ ទន្ទឹមនឹងនេះ ក៏ផ្តល់ប្រឹក្សាក្នុងការប្រើប្រាស់ឧបករណ៍នានាដែលមានចែងក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ដូចជា អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងក្របខ័ណ្ឌលទ្ធផល និងចែករំលែកបទពិសោធន៍ជាមួយលេខាធិការដ្ឋានរបស់ក្រុមការងារ (សូមមើលទំព័រទី ១១ ស្តីពីការគាំទ្រពីខាងក្រៅ) ។

ឆ- *មន្ត្រីបង្គោលរបស់ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កិច្ចការអន្តរវិស័យ* : មន្ត្រីបង្គោលទាំងនេះត្រូវចាត់តាំងដោយប្រធានក្រុមការងារបច្ចេកទេសចម្រុះ ដោយត្រូវពិគ្រោះយោបល់ជាមួយស្ថាប័នសាមី ។ ប្រសិនបើចាំបាច់ មន្ត្រីបង្គោលសម្រាប់កិច្ចការអន្តរវិស័យ អាចជាសមាជិកនៃក្រុមការងារបញ្ច្រាបយេនឌ័រ ការកែទម្រង់វិស័យសាធារណៈ បរិស្ថាន និងបម្រែបម្រួលអាកាសធាតុនៅតាមក្រសួង ឬស្ថាប័នពាក់ព័ន្ធ ។

ជ- *ទីប្រឹក្សាបច្ចេកទេសបំពេញការងារក្នុងគម្រោង ឬកម្មវិធីនៅតាមក្រសួងឬស្ថាប័នរាជរដ្ឋាភិបាល* : ទីប្រឹក្សាបច្ចេកទេស (សញ្ជាតិខ្មែរ ឬបរទេស) អាចចូលរួមកិច្ចប្រជុំរបស់ក្រុមការងារ ក្នុងឋានៈជាអ្នកជំនាញការ និងជាធនធានសំខាន់សម្រាប់អភិវឌ្ឍសមត្ថភាព ។ ប៉ុន្តែ ទីប្រឹក្សាទាំងនោះមិនអាចបំពេញតួនាទីជាប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ ឬមិនត្រូវបំពេញមុខងារជំនួសឱ្យក្រសួងនិងស្ថាប័នឡើយ ។

ឈ- *តំណាងសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល ឬវិស័យឯកជន* : ក្រុមការងារនីមួយៗអាចអញ្ជើញតំណាងអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល ឱ្យចូលរួមក្នុងក្រុមការងារ ។ តំណាងអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលទាំងនេះ ត្រូវមានតួនាទីប្រតិបត្តិការច្បាស់លាស់ ឬ/និងត្រូវផ្តល់ការគាំទ្រ ឬ/និងផ្តល់សេវានៅតាមវិស័យដែលពាក់ព័ន្ធនឹងក្រុមការងារ ។ លើសពីនេះ ក៏ត្រូវបង្ហាញអំពីសមត្ថភាព និងឆន្ទៈធ្វើជាតំណាងឱ្យអង្គការមិនមែនរដ្ឋាភិបាលទាំងមូល ព្រមទាំងត្រូវចែករំលែកព័ត៌មានពាក់ព័ន្ធនឹងគម្រោងដែលកំពុងអនុវត្ត តាមរយៈប្រព័ន្ធទិន្នន័យរបស់អង្គការមិនមែនរដ្ឋាភិបាលរបស់ គ. ជ. ន/ក. អ. ក ។ ក្នុងករណីចាំបាច់ ប្រធានក្រុមការងារអាចពិភាក្សាជាមួយប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ ដើម្បីអញ្ជើញតំណាងវិស័យឯកជនឱ្យចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមការងារ ។ ការកំណត់តំណាងវិស័យឯកជន

ឱ្យចូលរួមក្នុងក្រុមការងារ ក្នុងឋានៈជាសមាជិក ឬក៏ជាអ្នកសង្កេតការណ៍ ត្រូវផ្អែកលើសមត្ថភាពនៃការចូលរួមពិភាក្សារបស់តំណាងវិស័យឯកជន ។

### ២- ទំហំរបស់ក្រុមការងារបច្ចេកទេសចម្រុះ និងការប្រើប្រាស់អនុក្រុមការងារ

កន្លងមក កិច្ចប្រជុំពេញអង្គរបស់ក្រុមការងារដែលមានសមាជិកច្រើន បានផ្តល់កាលានុវត្តភាពសំខាន់ សម្រាប់ចែករំលែកព័ត៌មាន ។ ប៉ុន្តែ កិច្ចដំណើរការបែបនេះអាចរាំងស្ទះដល់ប្រសិទ្ធភាព និងការផ្លាស់ប្តូរយោបល់របស់កិច្ចប្រជុំ ។ ក្នុងស្មារតីនេះ ក្រុមការងារត្រូវមានរចនាសម្ព័ន្ធ និងទំហំសមល្មម ដែលមានតំណាងពីគ្រប់ភាគីពាក់ព័ន្ធ ហើយការពិភាក្សាត្រូវផ្តោតលើការសម្រេចលទ្ធផល ។ ក្នុងន័យនេះ ក្រុមការងារគប្បីអនុវត្តតាមគោលការណ៍ដូចខាងក្រោម ÷

ក- ប្រធានក្រុមការងារ និងប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ ដោយពិភាក្សាជាមួយសមាជិក ត្រូវកំណត់ចំនួនសមាជិកអតិប្បរមារបស់ខ្លួន ។

ខ- ក្នុងករណីតម្រូវឱ្យមានសមាជិកច្រើន ដែលស្ថានភាពនេះអាចប៉ះពាល់ដល់ប្រសិទ្ធភាពនៃកិច្ចពិភាក្សា ក្រុមការងារអាចបង្កើតក្រុមការងារស្នូល ដែលអាចជួបប្រជុំទៀងទាត់ ហើយត្រូវរាយការណ៍អំពីលទ្ធផលការងារជូនកិច្ចប្រជុំពេញអង្គរបស់ក្រុមការងារ ។ ទន្ទឹមនឹងនេះ ប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ និងតំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងក្រុមការងារស្នូល អាចចែករំលែកព័ត៌មានស្តីពីវឌ្ឍនភាពការងារដល់តួអង្គអភិវឌ្ឍន៍ដទៃទៀត ។

គ- ក្រុមការងារអាចបង្កើតអនុក្រុមការងារ (ដូចដែលធ្លាប់បានអនុវត្តក្នុងក្រុមការងារមួយចំនួន) ដើម្បីឆ្លើយតបនឹងការប្រែប្រួលស្ថានការណ៍ និងតម្រូវការរបស់ខ្លួន ។ អនុក្រុមការងារអាចជាយន្តការសម្រាប់ដោះស្រាយលម្អិត តាមបញ្ហាជាក់លាក់ ឬការងារជាប្រចាំ ឬតាមកាលបរិច្ឆេទកំណត់ ។ ការបង្កើតអនុក្រុមការងារមានសារៈប្រយោជន៍ សម្រាប់គាំទ្រដល់ការអនុវត្តការកែទម្រង់សំខាន់ៗ និងការអភិវឌ្ឍសមត្ថភាព ក៏ដូចជាសម្រាប់ដោះស្រាយបញ្ហាអន្តរវិស័យ ។ លទ្ធផលនៃកិច្ចពិភាក្សាក្នុងអនុក្រុមការងារត្រូវរាយការណ៍ជូនកិច្ចប្រជុំពេញអង្គរបស់ក្រុមការងារ ដើម្បីពិភាក្សា និងឯកភាពលើការងារចាំបាច់សម្រាប់អនុវត្តបន្ត ។

### ៣- កិច្ចដំណើរការប្រជុំរបស់ក្រុមការងារបច្ចេកទេសចម្រុះ

ដើម្បីធានាប្រសិទ្ធភាព ក្រុមការងារគប្បីយកចិត្តទុកដាក់ដល់ចំណុចដូចខាងក្រោម សម្រាប់រៀបចំក្រុមការងារក៏ដូចជាសម្រាប់កំណត់របៀបដំណើរការកិច្ចប្រជុំរបស់ខ្លួន ÷

ក- ផ្អែកលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រតាមវិស័យ និងសេចក្តីណែនាំនេះ ក្រុមការងារត្រូវរៀបចំលក្ខខ័ណ្ឌយោង ដែលកំណត់អំពីគោលបំណងជាក់លាក់ និងរបៀបរបបការងារ ដែលក្រុមការងារត្រូវប្រកាន់យក សម្រាប់គាំទ្រដល់ការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល (សូមពិនិត្យមើលផ្នែកទី ២ ខាងលើ) ។

ខ- ផែនការសកម្មភាពប្រចាំឆ្នាំ ដែលកំណត់អំពីអាទិភាពសម្រាប់ពិភាក្សាកម្រិតគោលនយោបាយ និងសូចនាករតាមដានរួមគ្នា ព្រមទាំងសកម្មភាពដទៃទៀតសម្រាប់ដោះស្រាយបញ្ហាអន្តរវិស័យ គឺជាមូលដ្ឋានក្នុងការរៀបចំកិច្ចប្រជុំ ដើម្បីធានាកិច្ចពិភាក្សាបានចំគោលដៅ ។

គ- ក្រុមការងារអាចជួបប្រជុំតាមការចាំបាច់ ប៉ុន្តែ គួរជួបប្រជុំយ៉ាងតិច ២ ដង ក្នុងមួយឆ្នាំ ។ កិច្ចប្រជុំនីមួយៗ ត្រូវមានរបៀបវារៈច្បាស់លាស់ និងមានសំណុំឯកសារចាំបាច់ ដែលត្រូវចែកជូនសមាជិក ឱ្យបាន ១០ ថ្ងៃ មុនពេលប្រជុំ ។

ឃ- ការប្រជុំត្រៀម ឬកិច្ចប្រជុំតាមដានវឌ្ឍនភាពការងារ រវាងប្រធានក្រុមការងារបច្ចេកទេសចម្រុះ និងប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ និងសមាជិកសំខាន់ៗ ក៏ដូចជាការប្រជុំត្រៀមរវាងដៃគូអភិវឌ្ឍន៍ អាចជួយឱ្យការពិភាក្សា និងការតាមដានវឌ្ឍនភាពរបស់ក្រុមការងារ បានចំគោលដៅ និងមានប្រសិទ្ធភាព ។

ង- កិច្ចប្រជុំនីមួយៗរបស់ក្រុមការងារ ត្រូវមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិភាក្សា ហើយសមាជិកទាំងអស់មានឱកាសគ្រប់ៗគ្នា សម្រាប់ជម្រាបអំពីវឌ្ឍនភាពការងារសំខាន់ៗរបស់ខ្លួន ជូនអង្គប្រជុំ ។

ច- ក្រសួង ឬស្ថាប័នសាម៉ី ត្រូវដោះស្រាយបញ្ហាប្រឈម ដែលមិនអាចដោះស្រាយនៅកម្រិតក្រុមការងារ ។ គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ គឺជាវេទិកាសម្រាប់ពិភាក្សាបញ្ហាដែលមិនអាចដោះស្រាយនៅកម្រិតក្រុមការងារ និងក្រសួង ឬស្ថាប័ន ។ ទន្ទឹមនឹងនេះ ក៏ជាវេទិកាសម្រាប់ដោះស្រាយបញ្ហាដែលមានចរិតអន្តរវិស័យផងដែរ ។ បញ្ហាទាំងនេះត្រូវរំលេចក្នុងរបាយការណ៍របស់ក្រុមការងារបច្ចេកទេសចម្រុះ មុនពេលកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ។

ឆ- បន្ថែមលើកិច្ចប្រជុំទៀងទាត់ ក្រុមការងារអាចរៀបចំអង្គវិបស្សនា ឬកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ ដើម្បីវាយតម្លៃលទ្ធផលការងារ និងប្រសិទ្ធភាពរបស់ក្រុមការងារ ដែលពាក់ព័ន្ធនឹងភាពជាដៃគូ រចនាសម្ព័ន្ធការគ្រប់គ្រង និងរបៀបរបបការងារ ព្រមទាំងការអភិវឌ្ឍសមត្ថភាព ។

### *៤- យន្តការគាំទ្រដល់ក្រុមការងារបច្ចេកទេសចម្រុះ*

*យន្តការគាំទ្រផ្ទៃក្នុង*

ប្រធានក្រុមការងារបច្ចេកទេសចម្រុះ និងប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ ត្រូវជួបប្រជុំទៀងទាត់សម្រាប់តាមដានវឌ្ឍនភាពការងារដែលបានឯកភាពគ្នា ពិសេស មុនកិច្ចប្រជុំរបស់ក្រុមការងារ ។ ការវាយតម្លៃកន្លងមកបានបង្ហាញថា ដំណើរការតាមរបៀបនេះអាចជួយពង្រឹងជំនឿទុកចិត្ត និងជំរុញឱ្យមានការពិភាក្សាដោយបើកចំហ ។

ការរៀបចំលេខាធិការដ្ឋានរបស់ក្រុមការងារបានល្អ ប្រកបដោយសមត្ថភាព និងមានធនធានគ្រប់គ្រាន់ នៅតាមក្រសួង ឬស្ថាប័ន គឺជាកិច្ចការចាំបាច់សម្រាប់គាំទ្រដល់ក្រុមការងារ ។ លេខាធិការដ្ឋានត្រូវបំពេញភារកិច្ចដូចខាងក្រោម÷

ក- រៀបចំលក្ខខ័ណ្ឌយោង និងអាណត្តិការងាររបស់ខ្លួនឱ្យបានច្បាស់លាស់ ។

ខ- រៀបចំកិច្ចប្រជុំ រៀបចំកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមការងារ ឬអនុក្រុមការងារ និងចែករំលែកព័ត៌មានទាំងនេះ ដល់សមាជិក នៅមុន ឬក្រោយពេលប្រជុំ ។

គ- ទំនាក់ទំនងជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ដើម្បីតាមដានវឌ្ឍនភាពក្នុងការអនុវត្តសកម្មភាពដែលបានឯកភាពក្នុងកិច្ចប្រជុំរបស់ក្រុមការងារ ។

ឃ- បំពេញតួនាទីជាចំណុចប្រមូលផ្តុំ សម្រាប់ទំនាក់ទំនងរវាងប្រធានក្រុមការងារ និងប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ ក៏ដូចជាសមាជិកដទៃទៀត ។

ង- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពរបស់ក្រុមការងារ និងរបាយការណ៍ស្តីពីវឌ្ឍនភាពក្នុងការអនុវត្តសូចនាករតាមដានរួមគ្នា ព្រមទាំងបំពេញតួនាទីជាចំណុចប្រមូលផ្តុំសម្រាប់សម្របសម្រួលជាមួយគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.នា/ក.អ.ក) ។

ដើម្បីចៀសវាងការបង្កើតរចនាសម្ព័ន្ធថ្មីបន្ថែម លេខាធិការដ្ឋានអាចជាផ្នែកមួយនៃរចនាសម្ព័ន្ធដែលមានស្រាប់របស់ក្រសួង ឬស្ថាប័ន ដូចជា នាយកដ្ឋានផែនការជាដើម ។ ក្រុមការងារត្រូវកៀរគរធនធាន ទាំងក្នុងប្រទេស ទាំងពីដៃគូអភិវឌ្ឍន៍ (អាចជាធនធានមួយផ្នែករបស់ក្រសួង និងស្ថាប័ន សម្រាប់អភិវឌ្ឍសមត្ថភាព ឬជាធនធានសម្រាប់គាំទ្រផ្ទាល់ដល់ក្រុមការងារ) ដើម្បីគាំទ្រសកម្មភាពរបស់លេខាធិការដ្ឋាន ។

*យន្តការគាំទ្រខាងក្រៅ*

គ.ជ.នា/ក.អ.ក ផ្តល់ការគាំទ្រដល់ក្រុមការងារ ក្នុងឋានៈជាចំណុចប្រមូលផ្តុំរបស់រាជរដ្ឋាភិបាល ក្នុងការសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ និងក្នុងឋានៈជាលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ។ តួនាទីគាំទ្រនេះមានសង្គតិភាពជាមួយយន្តការស្ថាប័ន ដែលបានរំលេចក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ហើយដែលមានខ្លឹមសារដូចខាងក្រោម ៖

> *គ.ជ.នា/ក.អ.ក ជាស្ថាប័នសម្របសម្រួល ដែលទទួលខុសត្រូវក្នុងការដឹកនាំរៀបចំគោលនយោបាយស្តីពីការកៀរគរ និងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ។ ក្នុងឋានៈជាលេខាធិការដ្ឋានសម្រាប់រៀបចំ និងគ្រប់គ្រងយន្តការពិគ្រោះយោបល់ គ.ជ.នា/ក.អ.ក ដឹកនាំកិច្ចពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ រៀបចំសូចនាករតាមដានរួមគ្នា និងតាមដានការអនុវត្តសូចនាករ ព្រមទាំងកត់ត្រាព័ត៌មានដែលពាក់ព័ន្ធនឹងគម្រោងរបស់ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ។ លើមូលដ្ឋាននេះ គ.ជ.នា/ក.អ.ក អាចផ្តល់ការគាំទ្រដល់ក្រុមការងារបច្ចេកទេសចម្រុះ ដូចជា ការគាំទ្រផ្នែកបច្ចេកទេសសម្រាប់រៀបចំ និងតាមដានការអនុវត្តសូចនាករតាមដានរួមគ្នាជាដើម ។*

មន្ត្រីបង្គោលរបស់ គ.ជ.នា/ក.អ.ក ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមការងារ ដើម្បីផ្តល់ការគាំទ្រចាំបាច់ ក៏ដូចជាផ្តល់ប្រឹក្សានានាដែលពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃកិច្ចអភិវឌ្ឍន៍ និងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ។ ទន្ទឹមនឹងនេះ ក៏អាចផ្តល់កិច្ចគាំទ្រចាំបាច់ដល់ក្រុមការងារ សម្រាប់អនុវត្តឧបករណ៍នានាដែលមានចែងក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ដូចជា អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងក្របខ័ណ្ឌលទ្ធផល ជាដើម ។

គ.ជ.នា/ក.អ.ក បំពេញតួនាទីជាមជ្ឈមណ្ឌលប្រមូលផ្តុំ និងចែករំលែកព័ត៌មាន ដល់ក្រុមការងារទាំងអស់ ព្រមទាំងរៀបចំកិច្ចប្រជុំរបស់បណ្តាញក្រុមការងារ ដោយមានការចូលរួមពីប្រធានក្រុមការងារ មន្ត្រីលេខាធិការដ្ឋាន តំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ។ កិច្ចប្រជុំនេះគឺជាកាលានុវត្តភាពសម្រាប់ចែករំលែកព័ត៌មាន និងដកស្រង់បទពិសោធន៍ ព្រមទាំងឯកភាពលើវិធានការដែលត្រូវអនុវត្តបន្ត ដើម្បីបង្កើនប្រសិទ្ធភាពរបស់ក្រុមការងារ ។

*៥- លក្ខណៈវិនិច្ឆ័យសម្រាប់បង្កើតក្រុមការងារបច្ចេកទេសចម្រុះថ្មី*

លក្ខណៈវិនិច្ឆ័យសម្រាប់បង្កើតក្រុមការងារបច្ចេកទេសចម្រុះ មានដូចខាងក្រោម ÷

ក- ក្រុមការងារត្រូវកំណត់គោលដៅច្បាស់លាស់ ដោយផ្អែកលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឬយុទ្ធសាស្ត្រតាមវិស័យ សម្រាប់ជួយគាំទ្រកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល តាមរយៈការអនុវត្តការងាររបស់ខ្លួន ។

ខ- មិនចាំបាច់បង្កើតយន្តការស្រប ឬយន្តការបន្ថែម ក្នុងករណីមានយន្តការសម្របសម្រួល និងចែករំលែកព័ត៌មានរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍រួចហើយ ។

គ- ក្រុមការងារត្រូវកំណត់ប្រធានបទ ឬវិស័យទទួលខុសត្រូវច្បាស់លាស់ ។ ក្នុងករណីចាំបាច់ អាចបង្កើតអនុក្រុមការងារសម្រាប់ដោះស្រាយបញ្ហានៅតាមសមាសភាគនីមួយៗនៃប្រធានបទ ឬវិស័យនោះ ។

ឃ- ក្រុមការងារមិនគួរកំណត់ប្រធានបទ ឬវិស័យឱ្យទូលំទូលាយពេកទេ ព្រោះអាចបង្កការលំបាកដល់ការកំណត់ភារកិច្ចទទួលខុសត្រូវ ក៏ដូចជាការតាមដានអំពីវឌ្ឍនភាពនៅតាមក្រសួង ឬស្ថាប័នពាក់ព័ន្ធ (បញ្ហាអន្តរវិស័យត្រូវបញ្ជ្រាបនៅតាមវិស័យ និងក្រុមការងារ) ។

ង- មុននឹងបង្កើត ឬរំលាយក្រុមការងារបច្ចេកទេសចម្រុះ ក្រសួង ឬស្ថាប័នសាមី ដោយបានពិភាក្សាជាមួយ គ.ជ.ន/ក.អ.ក ត្រូវរៀបចំសំណើជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសម្រេច ។

**ផ្នែកទី ៤ : គោលការណ៍សម្រាប់ធានាប្រសិទ្ធភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះ**

បទពិសោធន៍ក្នុងការគ្រប់គ្រងយន្តការស្តីពីភាពជាដៃគូនៅកម្ពុជា ក៏ដូចជាការត្រួតពិនិត្យ និងវាយតម្លៃកន្លងមកបានកំណត់គោលការណ៍សំខាន់ៗ ដើម្បីធានាប្រសិទ្ធភាពនៃភាពជាដៃគូ ។ គោលការណ៍ទាំងនេះត្រូវបានរំលេចក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ ២០១៤-២០១៨ ហើយត្រូវបានគូសបញ្ជាក់សារជាថ្មីនៅក្នុងសេចក្តីណែនាំនេះ ÷

ក- រាជរដ្ឋាភិបាលនឹងដឹកនាំភាពជាដៃគូប្រកបដោយបរិយាប័ន្ន ជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ដោយផ្តោតទៅលើការសម្រេចឱ្យបានលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ តាមរយៈការធ្វើការងាររួមគ្នា ទន្ទឹមនឹងការទទួលស្គាល់អំពីភាពសម្បូណ៌បែបរបស់បណ្តាតួអង្គទាំងនេះ ។

ខ- រាជរដ្ឋាភិបាល និងបណ្តាតួអង្គអភិវឌ្ឍន៍ ប្តេជ្ញាកសាងទំនាក់ទំនងការងារ ដោយឈរលើមូលដ្ឋាននៃទំនុកចិត្ត និងការគោរពគ្នាទៅវិញទៅមក ដោយផ្អែកលើក្របខ័ណ្ឌស្តីពីការគ្រប់គ្រងដោយផ្តោតលើលទ្ធផល និងក្របខ័ណ្ឌស្តីពីការតាមដានប្រកបដោយប្រសិទ្ធភាព ។

គ- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រតាមវិស័យ គឺជាមូលដ្ឋានសម្រាប់ឱ្យតួអង្គអភិវឌ្ឍន៍ទាំងអស់វិភាជន៍ធនធាន ធ្វើកម្មវិធីនីយកម្ម ក៏ដូចជាសម្រាប់ពិភាក្សា និងរៀបចំយន្តការតាមដាន ។ គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ ត្រូវចូលរួមជំរុញកិច្ចអភិវឌ្ឍន៍សង្គម- សេដ្ឋកិច្ច ប្រកបដោយចីរភាព និងសមធម៌ តាមរយៈការបង្កើនសមត្ថភាពផលិត និងការពង្រឹងមូលធនមនុស្សនៅកម្ពុជា ។

ឃ- គោលការណ៍ទាំងឡាយដែលមានចែងក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស នៅតែមានលក្ខណៈសមស្របសម្រាប់បន្តអនុវត្តនៅកម្ពុជា ។ រាជរដ្ឋាភិបាលទទួលយកទម្រង់ផ្តល់ហិរញ្ញប្បទានដែលបានពិភាក្សា និង

ឯកភាពរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ស្របតាមបទដ្ឋាន និងឧត្តមានុវត្តន៍ដែលបានឯកភាពនៅទីក្រុងប៉ារីស ឆ្នាំ ២០០៥ និងទីក្រុងអាក្រា ឆ្នាំ ២០០៨ ព្រមទាំងទីក្រុងប៊ូសាន ឆ្នាំ ២០១១ ។

ង- សុខដុមនីយកម្មក្នុងការគ្រប់គ្រង និងការប្រើប្រាស់ហិរញ្ញប្បទាននៅកម្រិតវិស័យ មានភាពកាន់តែប្រសើរឡើង ដោយសារមានដៃគូអភិវឌ្ឍន៍កាន់តែច្រើនបានឯកភាពអនុវត្តអភិក្រមរួមសម្រាប់កម្មវិធីនីយកម្ម ដូចជាអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ជាដើម ។

ច- ការអភិវឌ្ឍសមត្ថភាព គឺជាគោលដៅសំខាន់មួយនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ ជាទូទៅ កិច្ចសហប្រតិបត្តិការបច្ចេកទេស ត្រូវបានផ្តល់ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណង សម្រាប់អភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ក្រោមភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តគោលការណ៍ណែនាំស្តីពីតួនាទី និងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការបច្ចេកទេស ដែលបានអនុម័ត នាខែ កញ្ញា ឆ្នាំ ២០០៨ ហើយដែលបានបញ្ជាក់ថា ការប្រើប្រាស់កិច្ចសហប្រតិបត្តិការបច្ចេកទេសត្រូវមានសង្គតិភាពជាមួយគោលដៅនៃការអភិវឌ្ឍសមត្ថភាព ដូចបានកំណត់ក្នុងយុទ្ធសាស្ត្រ ឬផែនការរបស់រាជរដ្ឋាភិបាល ទន្ទឹមនឹងការយកចិត្តទុកដាក់ដល់បរិស្ថានអនុវត្តការងារផងដែរ ។ លើសពីនេះ គំនិតផ្តួចផ្តើមនានាសម្រាប់ពង្រឹងសមត្ថភាព និងការផ្តល់កិច្ចសហប្រតិបត្តិការបច្ចេកទេស ត្រូវតែផ្សារភ្ជាប់ជាមួយកម្មវិធីកែទម្រង់ស្នូលនានារបស់រាជរដ្ឋាភិបាល ។

គោលការណ៍ខាងលើនេះមានសង្គតិភាពជាមួយរបបគំហើញនៃរបាយការណ៍វាយតម្លៃស្តីពីប្រសិទ្ធភាពការងាររបស់ក្រុមការងារ ឆ្នាំ ២០១៤ ។ របបគំហើញនេះបានឆ្លុះបញ្ចាំងថា ភាពជាម្ចាស់ដ៏រឹងមាំរបស់រាជរដ្ឋាភិបាល ការប្តេជ្ញាខ្ពស់របស់ប្រធានក្រុមការងារ ការគាំទ្ររបស់ប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ សមត្ថភាព ទាំងការគ្រប់គ្រង ទាំងខាងបច្ចេកទេសរបស់លេខាធិការដ្ឋាន ជំនឿទុកចិត្តគ្នាទៅវិញទៅមក និងទំនាក់ទំនងល្អ ព្រមទាំងការចំណាយពេលវេលាគ្រប់គ្រាន់ និងកិច្ចខិតខំប្រឹងប្រែងរបស់ភាគីពាក់ព័ន្ធ គឺជាកត្តាសំខាន់សម្រាប់លើកកម្ពស់ប្រសិទ្ធភាពរបស់ក្រុមការងារ ។

### ***ការអនុវត្តគោលការណ៍ស្តីពីភាពជាដៃគូ***

ក្រុមការងារបច្ចេកទេសចម្រុះមួយចំនួនបានរៀបចំគោលការណ៍នៃភាពជាដៃគូ សម្រាប់បំពេញបន្ថែមឱ្យលក្ខខ័ណ្ឌយោងរបស់ខ្លួន ដើម្បីកំណត់នីតិវិធីអនុវត្តការងារក្នុងក្របខ័ណ្ឌនៃគណនេយ្យភាពទ្វេទិស ។ គោលការណ៍នៃភាពជាដៃគូមានសារៈសំខាន់ ដើម្បីកំណត់អំពីរបៀបរបបចាត់ចែងកិច្ចពិភាក្សា និងបង្កើតយន្តការរួមសម្រាប់គ្រប់គ្រងកម្មវិធីការងារ ដូចជា ការកំណត់អាទិភាព ការប្រើប្រាស់ធនធាន ការរៀបចំរបាយការណ៍ និងការវាយតម្លៃ ជាដើម ។ ដើម្បីជំរុញភាពជាម្ចាស់ និងភាពជាដៃគូ ព្រមទាំងដើម្បីឈានទៅសម្រេចលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ នៅពេលរៀបចំគោលការណ៍ស្តីពីភាពជាដៃគូ ក្រុមការងារគប្បីពិចារណាលើចំណុចដូចខាងក្រោម ÷

ក- ក្រុមការងារគឺជាយន្តការសម្របសម្រួលដើម្បីគាំទ្ររាជរដ្ឋាភិបាលក្នុងការសម្រេចឱ្យបាន នូវលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ ស្របតាមផែនការជាតិ និងផែនការវិស័យ ។

ខ- គោលការណ៍ស្តីពីភាពជាដៃគូ ត្រូវផ្អែកលើបរិការណ៍ទាំងខាងគោលនយោបាយ ទាំងខាងស្ថាប័ន ដែលបានកំណត់ក្នុងគោលដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការវិស័យ ។ គោលការណ៍ទាំងនេះត្រូវ

ផ្សារភ្ជាប់ទៅនឹងអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ដែលផ្តោតជាសំខាន់ ទៅលើការពង្រឹងភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល ។

គ- មុនពេលចរចាសម្រាប់រៀបចំគោលការណ៍ស្តីពីភាពជាដៃគូ ប្រធានក្រុមការងារត្រូវមានជំនឿជឿជាក់លើសមត្ថភាពរបស់ខ្លួន ក្នុងការដឹកនាំកិច្ចចរចានេះ ហើយត្រូវធានាថា គោលការណ៍ស្តីពីភាពជាដៃគូនេះនឹងផ្តល់តម្លៃបន្ថែមដល់កិច្ចប្រឹងប្រែងរបស់ភាគីពាក់ព័ន្ធ ក្នុងគោលដៅពង្រឹងភាពជាដៃគូ និងសម្រេចលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ ។

ឃ- គោលការណ៍ស្តីពីភាពជាដៃគូ ត្រូវមានសង្គតិភាពជាមួយក្របខ័ណ្ឌជាតិស្តីពីភាពជាដៃគូ ដូចជា យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ និងការប្តេជ្ញាកម្រិតសាកលនានាដែលមានចែងក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ឆ្នាំ ២០០៥ ផែនការសកម្មភាពទីក្រុងអាក្រា ឆ្នាំ ២០០៨ និងសេចក្តីថ្លែងការណ៍ទីក្រុងប៊ូសាន ស្តីពីភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ ឆ្នាំ ២០១១ ។

ង- គោលការណ៍ស្តីពីភាពជាដៃគូត្រូវបញ្ជាក់ច្បាស់អំពីគោលបំណង ដូចជា សេចក្តីថ្លែងការណ៍រួមស្តីពីគោលដៅដែលត្រូវអនុវត្តឱ្យបានសម្រេច ។ គោលការណ៍ទាំងនោះត្រូវកំណត់អំពីភារកិច្ចទទួលខុសត្រូវ ការប្តេជ្ញាពីសមាជិកទាំងអស់ និងសកម្មភាពដែលត្រូវអនុវត្ត ដើម្បីឈានទៅសម្រេចគោលដៅដែលបានកំណត់ ហើយមិនត្រូវរំលេចលម្អិតអំពីសកម្មភាពការងារ ព្រោះកិច្ចការទាំងនេះត្រូវរំលេចនៅក្នុងផែនការសកម្មភាព ឬក្របខ័ណ្ឌតាមដាន ។

ច- គណនេយ្យភាពទ្វេទិសត្រូវរំលេចក្នុងគោលការណ៍ស្តីពីភាពជាដៃគូ ។ នេះមានន័យថា ភាគីទាំងសងខាងត្រូវបញ្ជាក់អំពីវិធីសាស្ត្រនៃការបំពេញការងាររួមគ្នា សម្រាប់រៀបចំ និងអនុវត្តផែនការ ក៏ដូចជាសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាព ។ គោលការណ៍ស្តីពីភាពជាដៃគូនេះត្រូវយកចិត្តទុកដាក់ដល់ការធានាឱ្យមានតុល្យភាពរវាងការប្តេជ្ញារបស់បណ្តាភាគីពាក់ព័ន្ធទាំងអស់ ជាមួយនឹងតួនាទី និងសមត្ថភាពរបស់ភាគីនីមួយៗ ។

ឆ- គប្បីកុំប្រើប្រាស់ភាសា ឬពាក្យពេជន៍មួយចំនួន ដែលអាចកាត់បន្ថយអត្ថន័យ តម្លៃ និងគោលបំណងនៃគោលការណ៍ស្តីពីភាពជាដៃគូនេះ ដូចជា «ខិតខំអនុវត្តឱ្យបានច្រើនតាមដែលអាចធ្វើបាន» ឬ «អនុវត្តជាជំហានៗ» និង «អនុវត្តក្នុងរយៈពេលណាមួយ» ជាដើម ។

ជ- គោលការណ៍នៃភាពជាដៃគូត្រូវកំណត់គោលដៅ ពេលវេលា និងយន្តការតាមដានឱ្យបានច្បាស់លាស់ ។

ឈ- រៀបចំក្របខ័ណ្ឌសម្រាប់តាមដានការអនុវត្តគោលការណ៍ស្តីពីភាពជាដៃគូ ដោយបញ្ជាក់អំពីគោលដៅ និងពេលវេលាជាក់លាក់ ដែលត្រូវរំលេចក្នុងផែនការត្រួតពិនិត្យប្រចាំឆ្នាំ ។

ញ- សេចក្តីណែនាំស្តីពីការប្រើប្រាស់កិច្ចសហប្រតិបត្តិការបច្ចេកទេសប្រកបដោយប្រសិទ្ធភាព គឺជាមូលដ្ឋានបង្អែក សម្រាប់ដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍សមត្ថភាព និងកិច្ចសហប្រតិបត្តិការបច្ចេកទេស ។